សារព័ត៌មាន ខ្មែរប៉ុស្ដិ៍ ស.រ.អា
KhmerPost USA
E-mail: info@khmerpost.us / Website : khmerpost.us
Advertising: 978-656-8141/ Hotline news: 978-942-1641

មាតិការឿង

Issue 172 Mar. 8th. - 20th 2015

Free

១-ដំណើរពីអាមេរិកទៅអាស៊ី (ភាគ៨)................០២
២-កម្មវិធីផ្សេងៗនៅក្នុងគ្រួសារ.........................០៥
៣-តម្លៃផ្ទះកំពុងឡើងថ្លៃ.................................១០
៤-ប័ណ្ណអនុញ្ញាតបើកបរអន្តរជាតិ........................១២
៥-ឯកសារផ្ទៃក្នុងអគ្គបញ្ហាការកងទ័ព..................២០
៦-បាញ់ទឹកអប់ដូចម្ដេច ទើបក្លិនក្រអូប..................២២
៧-ចំការស្ពៃបារ័រមណីយដ្ឋានកំពុងជាទីចាប់..............២៥
៨-ចំណីអាហារ៩ប្រភេទជួយដល់សុខភាព.................៣០

**Office:** Tel: (978) 677-7163 Fax: (978) 677-7092
45 Merrimack St. Suite 218A Lowell, MA 01852

## វិចារណកថា

# នយោបាយទប់ក្បាលបង្គួរ ឈាមខ្មែរ

**ដោយ : ពិន សំខុន**

កិច្ចចរចារវាងគណបក្សប្រជាជននឹងគណបក្សសង្គ្រោះជាតិស្ដីអំពីការបង្កើតគ.ជ.ប.ថ្មីបានបញ្ចប់ទៅដោយជោគជ័យនៅដាច់ខែកុម្ភៈ២០១៥ តាមកាលកំណត់



លោក សម រង្ស៊ី និង លោក ស ខេង បានបញ្ចប់ការងារបង្កើតគជបថ្មី

បើតាមសេចក្ដីថ្លែងការណ៍របស់លោក ស ខេង ខាងគណបក្សប្រជាជននឹងលោក សម រង្ស៊ី ខាងគណបក្សសង្គ្រោះជាតិនៅសល់តែ **តទៅទំព័រទី ០៨**



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

នាយកដ្ឋានព័ត៌មាន និងឯកសារ

សេចក្ដីជូនព័ត៌មាន

លោកជំទាវ មីស្ហែល អូបាម៉ា (Michelle Obama) ដែលជាជំទាវទី១ និងជាភរិយារបស់ឯកឧត្តម បារ៉ាក់ អូបាម៉ា (Barack Obama) ប្រធានាធិបតីសហរដ្ឋអាមេរិក នឹងអញ្ជើញមកបំពេញទស្សនកិច្ចវប្បធម៌ជាផ្លូវការ នៅព្រះរាជាណាចក្រកម្ពុជា ចាប់ពីថ្ងៃទី ២០ ដល់ ២២ ខែ មីនា ឆ្នាំ ២០១៥ ។

Her Excellency Ms. Michelle OBAMA, First Lady and Spouse of His Excellency Mr. Barack OBAMA, President of the United States of America, will pay an official cultural visit to the Kingdom of Cambodia from 20 to 22 March 2015.

រាជរដ្ឋាភិបាលកម្ពុជា សូមស្វាគមន៍យ៉ាងកក់ក្ដៅ នូវដំណើរទស្សនកិច្ចរបស់លោកជំទាវ មីស្ហែល អូបាម៉ា ហើយសង្ឃឹមថា ដំណើរទស្សនកិច្ចដ៏សំខាន់នេះ ក៏នឹងពង្រឹងចំណងមិត្តភាព និងកិច្ចសហប្រតិបត្តិការ រវាងព្រះរាជាណាចក្រកម្ពុជា និងសហរដ្ឋអាមេរិក ផងដែរ ។

ភ្នំពេញ ថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០១៥



# វត្តត្រៃរតនារាមផុសចេញពីព្រិលឆ្នាំ២០១៥

## Trayratanaram Temple survived from snowiest season

វិហារដែលធ្លាប់ល្បីល្បាញជាងគេកាលពី២០ឆ្នាំមុននៃវត្តត្រៃរតនារាមនៅឡូវែលបានទទួលរងគ្រោះខ្លាំងជាងគេនារដូវរងារឆ្នាំនេះ ពីព្រោះមិនត្រឹមតែទទួលរដូវរងារដ៏ត្រជាក់បំផុតនឹងរងការធ្លាក់ព្រិលខ្លាំងជាងគេក្នុងសហរដ្ឋតែប៉ុណ្ណោះទេ ថែមទាំងពុទ្ធបរិស័ទ គណកម្មការអាចារ្យវត្ត ព្រមទាំងព្រះសង្ឃ រួមទាំងគូរប្រយុទ្ធស្លាប់រស់នៃវត្តលើ-វត្តក្រោម ក៏បានចាកចោលអស់រលីង ធ្វើឱ្យវិហារនេះ រងារស្ទើរបាក់ដំបូល បែកបំពង់ នឹងពុកឈើគ្មានអាណិត ។ នៅពេលដែលព្រិល **តទៅទំព័រទី ២៣**




ការិយាល័យ មេធាវី
ថំមាស ស្ទាលីយ៉ាណូស
Law Office of Thomas Stylianos Jr.
287 Appleton St. Lowell MA 01852
• Immigration •អន្តោប្រវេសន៏
• Auto Crash •គ្រោះថ្នាក់រថយន្ត
• Divorce •លែងលះប្ដីប្រពន្ធ
សូមទាក់ទង សោភា ឬ ធំ 978-459-5000 or 800-308-3766

# ដំណើរពីអាមេរិកទៅអាស៊ី (ភាគ៨)

**តពីលេខមុន**

**ដោយ : ពិន សំខុន**

ថ្ងៃទី៦វិច្ឆិកា២០១៤ សូបិន ខ្ញុំ នឹង ប៉ុណ្ណារ៉ូ បានលាកូនស្រី ចៅៗ នឹងមិត្តភ័ក្រ្តបារាំងខ្មែរទាំងអស់ឡើងយន្តហោះទៅកាន់ព្រៃនគរដែលដំណើរនេះ ខ្ញុំបាន"រាយរ៉ាប់ជូនជាសណ្តាប់រួចហើយ កាលពីកាសែតលេខមុនៗ ស្តីអំពី"ដំណើរទៅលេងគ្រួសារនៅបាយឆៅប្រទេសកម្ពុជាក្រោម"ដែលខ្ញុំសរសេរឱ្យឆាប់ចប់ ដើម្បីកុំឱ្យភ្លេចចុងភ្លេចដើមនាំពិបាកយល់ ។ ឥឡូវខ្ញុំសូមបន្តរដំណើរដដែលនេះ ចាប់ពីខ្ញុំត្រឡប់ពីព្រៃនគរមកកាន់ភ្នំពេញវិញ ។ មកដល់ភ្នំពេញវិញ ថ្ងៃទី១៣ វិច្ឆិកា២០១៤មុន១ថ្ងៃនៃពិធីមង្គលការកូនប្រុសឈ្មោះ វិរវិត្រ ហៅ លុច ជាកូនកំសត់កំរជាមួយគ្នានៅរាជធានីបាងកកពេលនៅជាជនភៀសខ្លួន នឹងនៅរដ្ឋធានីវ៉ាស៊ីនតុននឹងនៅពេលកូនចូលទៅរៀនជាមួយសិស្សអាមេរិកាំងជាមួយពេលខ្ញុំធ្វើការឱ្យ"អាស៊ីសេរី" ហើយមានការស្រឡាញ់ វាដូចជាកូនខ្ញុំបង្កើតដែរ រហូតដល់មានមិត្តភ័ក្រ្តខ្លះគេចំអកឱ្យខ្ញុំថា"ខិតខំលាក់ការពិតដែលអាលុច គឺជាកូនលួចលាក់របស់ខ្ញុំ"។ ធ្វើឪពុកម្នាក់ឯងចិញ្ចឹមកូនពេញជំទង់បីនាក់ គឺទេវី - មីរ៉ាជី នឹងអាលុចប្រាកដជាមិនជាស្រួលប៉ុន្មានទេ តែយើងបានស្រូតរហូតបានដល់ទីបញ្ចប់គ្រប់ៗគ្នាបានយ៉ាងលំបាក ហើយពិតជាអាចសរសេរសៀវភៅរឿងមួយបានយ៉ាងក្រាស់ពីវាសនាឡើងចុះនៃគ្រួសារយើងទម្រាំមកដល់ថ្ងៃនេះ។ នៅភ្នំពេញខ្ញុំត្រូវតែខំរៀបកម្មវិធីដំណើររបស់ខ្ញុំឱ្យចំថ្ងៃការកូនស្រីផង នឹងកូនប្រុសផង រៀបចំនៅ



ពិធីមង្គលការ លីន និង វីរៈចិត្រ

ថ្ងៃមង្គលខុសគ្នា១ខែ រីឯដំណើររបស់ សុបិន គ្រោងនឹងមកចូលរួមដែរ ប៉ុន្តែការចំណាយនឹងពេលវេលាមិនអំណោយផលទេ រីឯកាងារកាសែត"ខ្មែរផុស ស.រ.អា."របស់យើងវិញ នៅតែចេញផ្សាយរៀងរាល់ពីរសប្តាហ៍ម្តងនៅសហរដ្ឋអាមេរិកក្រោមការគ្រប់គ្រងរបស់សូបិន ឥតមានសម្រាកបានឡើយ ។

ពិធីការរបស់កូនខ្ញុំគេរៀបចំហ៊ុកហ៊ាក់ខ្លាំងណាស់ភរិយារបស់គេឈ្មោះ នាងលីន ជានារីក្មេងរូបសម្ផស្សស្រស់ស្អាតហើយរស់រាយណាស់ អ្នកជន្លងខ្ញុំគឺ"នាយក្រឹម"សិល្បករដ៏ល្បីល្បាញនៅស្រុកខ្មែរដែលធ្វើឱ្យខ្ញុំភ្ញាក់ផ្អើលជាខ្លាំងនៅពេលកូនប្រុសខ្ញុំបង្ហាញជាលើកដំបូងថា "នេះហើយជាឪពុកក្មេកខ្ញុំ!"យើងបានស្គាល់គ្នាជាមុនហើយទេតើ! ជារឿងគួរឱ្យរីករាយមែនដែលកូនខ្ញុំចេញពីមហាវិទ្យាល័យនៅ"ម៉ាយ៉ាមី"ភ្លាមបែរជាព្យួថាមករកស៊ីធ្វើការនៅស្រុកខ្មែរ ខ្ញុំមិនបានសប្បាយចិត្តទេពីដំណឹងនេះតែដល់ឮថាវាបំរុងក៏សាងគ្រួសារ ក៏មានអារម្មណ៏



ឪពុកក្មេង (នាងក្រឹម) និងកូនប្រសារ

ប្រសើរបន្តិច ពីព្រោះអាលុចមានមានមាមីងជា

**តទៅទំព័រទី ០៤**




SFS THE SCHOOL FOR FIELD STUDIES

# សម្រាប់ការចេញផ្សាយជាបន្ទាន់

**The School for Field Studies (SFS) បានបង្កើតអាហារូបករណ៍កម្ពុជា-អាមេរិក សម្រាប់និស្សិតដែលមានឈាមជ័រខ្មែរ**

*អាហារូបករណ៍ក្នុងកម្មវិធីសិក្សាផ្នែកបរិស្ថានរយៈពេលមួយឆមាសផ្តល់ដោយ SFS ក្នុងប្រទេសកម្ពុជា*

ទីក្រុង Beverly, រដ្ឋ Massachusetts ប្រទេសសហរដ្ឋអេមេរិកថ្ងៃទី៤ ខែមីនា ឆ្នាំ២០១៥ -នៅថ្ងៃនេះ The school for Field Studies (SFS) ដែលជាកម្មវិធីសិក្សាក្រៅប្រទេសធំជាងគេបំផុតក្នុងសហរដ្ឋអាមេរិកផ្នែកបរិស្ថានសម្រាប់និស្សិតបរិញ្ញាប័ត្របានប្រកាសពីការបង្កើតអាហារូបករណ៍ថ្មីមួយ ដើម្បីជួយឧបត្ថម្ភដល់និស្សិតដែលមានដើមកំណើតជាជនជាតិកម្ពុជា។ អាហារូបករណ៍កម្ពុជា-អាមេរិកដែលជាផ្នែកមួយនៃកម្មវិធីអាហារូបករណ៍បេតិកភណ្ឌរបស់ SFS ជួយឧបត្ថម្ភនិស្សិតកម្ពុជា-អាមេរិកដែលបានចុះឈ្មោះរៀនក្នុងកម្មវិធីសិក្សាក្រៅប្រទេសផ្នែកបរិស្ថានរយៈពេលមួយឆមាសរបស់ SFS ដែលមានឈ្មោះថា "The Living Mekong" នៅក្នុងប្រទេសកម្ពុជា។ **តទៅទំព័រទី ០៧**



# The School for Field Studies (SFS) Establishes Cambodian American Scholarship for Students of Cambodian Heritage

*ScholarshipSupports College Semester Environmental Studies Program with SFS in Cambodia*

Beverly, Massachusetts, USA, March 4,2015 - Today, The School for Field Studies (SFS), the U.S.'s largest environmental study abroad program for college undergraduates, announced the establishment of a new scholarship supporting students of Cambodian descent. The Cambodian-American Scholarship, part of SFS's Heritage Scholarship program, supports Cambodian American students who enroll in "The Living Mekong," SFS's semester-length environmental study abroad program in Cambodia.

Introduced last September, "The Living Mekong: Conservation, Water and Development in a Changing Climate" program is a semester length environmental study abroad program based in Siem Reap. This unique field-based academic program examines the importance of the Mekong River as a source of livelihood for millions of people. The Living Mekong is operated in the fall and spring semesters each year, and offers an opportunity for undergraduate students to work with SFS faculty on important environmental research regarding the impact of climate change, urbanization and agriculture on the ecosystems that comprise the Mekong region. Students receive 18 semester hours of academic credit. The term culminates with a directed research project in which the students design and carry out environmental field work, then present their findings to local communities in the region.

To learn more about the Living Mekong semester abroad program, visit: http://www.fieldstudies.org/mekong.

To learn more about the SFS Heritage Scholarship, please visit http://www.fieldstudies.org/admissions/aid or email admissions@fieldstudies.org.



## តមកពីទំព័រទី ០២ ដំណើរពីអាមេរិកទៅអាស៊ី...

ច្រើនដែលចង់ឱ្យវារកគ្រួសារបានសមប្រកប ពីព្រោះអាយុក៏ជាង៣០ទៅហើយ វាជាមនុស្សសមតែមានសំណាងល្អដោយសារលក្ខណៈសម្បត្តិវាជាមនុស្សឆ្លាត សុច្ចរិត ជួយយកអាសារអ្នកដំទៃ ដោយចេះលះបង់ពីមាត់ខ្លួនឯងបានយ៉ាងងាយស្រួលជាពិសេសទៅទៀតនោះ ជាអ្នកធ្វើការប្រឹងប្រែងប្រកបដោយការពិចារណា ។ ម្តាយអាលុចឈ្មោះចាន់រី រស់នៅប្រទេស "ន័រវេស៍"ក៏មកការកូនខ្លួននៅភ្នំពេញដែរ ។

អាលុចជាសាវគ្គព្រះ"យីស៊ូគ្រីស្ទ" តាំងតែពីនៅបាងកកម្ល៉េះ ខ្ញុំយល់ថា ជាការល្អណាស់ដែលមានជំនឿលើព្រះណាមួយមិនមានទំនាស់ជាមួយខ្ញុំដែលជាអ្នកកាន់ព្រះពុទ្ធសាសនានោះទេ ។ ខ្ញុំតែងលើកទឹកចិត្តឱ្យអាលុចទៅព្រះវិហាររបស់គេរឿងរាល់ពេលដែលធ្វើទៅបាន ហើយមានទាំងជូនទៅពិធីនានានៃបុណ្យរបស់ព្រះគេទៀតផង រហូតដល់មានពេលមួយនោះ យកគេទៅផ្ញើរលោកគ្រូគង្វាលមួយរយៈដោយសារមិនអាចប្តូរសាលារៀនបាននៅពេលដែលខ្ញុំប្តូរផ្ទះទៅនៅទីឆ្ងាយ ។ ឆ្នាំនោះទោះជាយើងនៅឆ្ងាយពីគ្នាមែនតែអាលុចគេក៏បាននៅក្បែរព្រះរបស់គេក្នុងជំនឿគ្មានរៀចរេដែរ ។ នៅថ្ងៃមង្គលការរបស់គេ គេមិនបានភ្លេចមិត្តភ័ក្រ្តនៃសាសនាគ្រីស្តនោះទេ គេបានប្តើមឧទ្ទិសមង្គលការនៅចំពោះព្រះភ័ក្រ្តព្រះរបស់គេយ៉ាងត្រចះត្រចង់នាសណ្ឋាគារដ៏ធំមួយ នាកន្លែងប្រសព្វទន្លេ៤មុខនៃទីក្រុងភ្នំពេញផង ។

ស្អែកឡើងពិធីមង្គលការតាមទំនៀមទំលាប់ខ្មែរតាំងពីព្រលឹមនៅគេហដ្ឋានខាងស្រីស្ថិតនៅម្តុំទួលគោកមិនឆ្ងាយប៉ុន្មានពី"អង់តែន"ទូរទស្សន៍ ។ ព្រហ៊ាមនោះ ខ្ញុំមានមានបញ្ហាស្ទើរដោះមិនរួចមួយដោយខ្វះអាវក្នុងត្រូវនឹងអាវកត្រង់ចេញពីហាងកាត់ដេរ"ប៉ារ៉ាឌី"គួរឱ្យចង់ពាក់មួយនឹកថា អាចរកបានស្រួលខំរកអស់ចិត្តសំណាងល្អមានហាងតូចមួយបើកទទួលភ្ញៀវតាំងពីព្រលឹមស្រាង៧ស្ថិតនៅប្រមាណ៥នាទីពីផ្ទះការបើកុំតែបាន "ប៊ុនឡេង"ជាកូនក្មួយជូនផ្លូវកុំអីទៅការកូនទាំងគ្មានអាវក្នុងទៅហើយ ។ រោងការយ៉ាងវែងសង់កាត់ផ្លូវមួយទាំងមូលលំអដោយផ្កាភ្ញីគ្មានចន្លោះទទួលភ្ញៀវទទួលអ្នកភ្លេង អ្នករៀបពិធី អាចារ្យ ព្រះសង្ឃ...។ បន្តបន្ទាប់សិល្បៈករល្បីៗ ដូចជាស្មៀនម៉ាញ នាងសារីជាដើមបន្ត កន្ទុយ មកច្រៀង រាំ ជូនពរ ចងដៃ បាចផ្កាស្លា ឱ្យកូនស្រីប្រុស របស់មិត្តរួមសិល្បៈយ៉ាងសែនរីករាយក្រៃលែង ។



ពិធីមង្គលការមានលោកជំទាវ ប៊ុនរ៉ានី ហ៊ុន សែន ចូលរួមដែរ

ភ្ញៀវជាច្រើនសុទ្ធសឹងអ្នកឆ្លៀតឱកាសទំនេរពីកង្វល់កាងារបន្តិច មកចងដៃ មករួមជប់លៀងស្រស់ស្រូប ឬថ្ងៃត្រង់ជាកិត្តិយសដល់នាយក្រមនឹងភរិយាយ៉ាងអ៊ឹកធឹក ។ ភ្ញៀវពិសេសម្នាក់ដែលតែខ្សឹបខ្សៀវរង់ចាំជាកិត្តិយសនឹងទំនងជាគ្រួសារផងនោះ គឺលោកជំទាវ ហែម ប៊ុនហេង ជាស្ត្រីអាយុប្រមាណតិច៤០ឆ្នាំ តែរូបសម្ផស្សស្អាតតែងខ្លួនសំលៀកបំពាក់ខ្មែរ ទទួលទូរស័ព្ទច្រើនទំនងជាម្ចាស់ពាណិជ្ជកម្មមាញឹកដែលមកចូលរួមចងដៃបាចផ្កាស្លា កាត់សក់ ហើយទទួលគារវកិច្ចពីភ្ញៀវឯទៀតគ្រប់គ្នា រហូតដល់ចប់មុននឹងទៅរៀបខ្លួនសម្រាប់ទៅជប់លៀងពេលល្ងាចនៅភោជនីយដ្ឋានដ៏ល្បីឈ្មោះនាបច្ចុប្បន្ននៅកោះពេជ្រ។ ប៉ុន្តែសម្រាប់ខ្ញុំមិនអាចនៅចូលរួមពិធីជប់លៀងនោះបានទេ ដោយអាលុចដឹងថាខ្ញុំមានជើងដំណើរ នាថ្ងៃស្អែកនៅម៉ោង១០ព្រឹកពីព្រៃនគរទៅហុងកុងតែគ្មានជើងយន្តហោះពីភ្នំពេញទៅព្រៃនគរណាក្រោយពីម៉ោង៧ល្ងាចថ្ងៃនេះ ទៅឱ្យទាន់ពេលនោះទេ ជើងដំណើរនោះលើកទៅពេលផ្សេងក៏មិនបានទៀត តែលើកគឺនឹងត្រូវលប់ដំណើររហូតដល់សហរដ្ឋអាមេរិកទាំងអស់ ។ ដូច្នេះខ្ញុំក៏លាអ្នកជន្លងកូនប្រសារកូនបង្កើតនឹងម្តាយអាលុចនឹងក្រុមគ្រួសារ នារសៀលនោះតែម្តងយ៉ាងអាឡោះអាល័យដោយមិនដឹងថានឹងបានជួបគ្នាពេលក្រោយណាទៀតទេ ។ ខ្ញុំបានឃើញថា កូនស្រីនឹងគូនប្រុសខ្ញុំទាំង២នេះ ដៃធំណាស់មង្គលការរៀបធំដ៏យ៉ាងនេះនាំឱ្យខ្ញុំបារម្ភណ៏ច្រើន

តទៅទំព័រទី ០៦



The City of LOWELL

# 15th Annual Lowell WinterFest



## Friday and Saturday, March 13 & 14, 2015

### ថ្ងៃសុក្រ និងថ្ងៃសៅរ៍ ត្រូវនិងថ្ងៃទី១៣,១៤ ខែមិនា ២០១៥

Visit www.Lowell.org for Event Updates! សូមអញ្ជើញចូលរួមដោយរីករាយ!

# បុណ្យសិសិររដូវឆ្នាំទី១៥នៅក្រុងឡូវែល

**FRIDAY, March 13 :**

All evening Projections on City Hall and JFK Plaza - Street food and Grilling Theater on Arcand Drive

ពេញមួយរសៀល បញ្ចាំងរូបភាពនៅសាលាក្រុង និងនៅJFKផ្លាសា និងមានម្ហូបចំណីតាមដងផ្លូវ មានសាច់អាំង នៅផ្លូវ Arcand Drive,

**5:30 PM.** Opening Ceremony on the Human Dogsled track on Arcand Drive.បើកកម្មវិធី អូសរទេះលើទឹកកកនៅផ្លូវ Arcand Drive.

**5PM - 10PM:** Family Fun at Lucy Larcom Park, លេងល្បែងសម្រាប់គ្រួសារនៅឧទ្យាន Lucy Larcom Park.

**6PM – 9PM** Micro and Craft Brewers Competition & Showcase. Tickets sale at www.Lowell.org,

ប្រជែងគ្នាផឹកស្រាបៀរ និងតាំងតុពិពណ៌ ទិញសំបុត្រតាមរយៈវ៉ែបសៃ WWW.Lowell.Org

-Hot Roasted marshmallows on Arcand Drive ដុត"ម៉ាសម៉ាឡូ" នៅផ្លូវ Arcand Drive

**7PM, 8PM, and 9PM:** Live Fire Show with Cirque de Light at Lucy Larcom Park, មានលេងសៀកនៅឧទ្យាន (Lucy Larcom)

**07:15PM :** UMas Lowell Men´s Hockey Playoff at UMass Lowell Tsongas center ប្រកួតផ្តាច់ព្រ័ត្រកីឡាហូកគីលើទឹកកកនៅ មណ្ឌលសុងហ្គា មហាវិទ្យាល័យក្រុងឡូវែល

- 9PM – Midnight: Live Music atClub Celsius on Arcand Drive. Tickets are $5 at the door, cash only. Age 21+ only.

**អាធ្រាត:** នឹងមានសំដែងដូតន្ត្រីនៅ Club Celsius ផ្លូវ Arcand Drive, មានលក់សំបុត្រនៅទ្វារចូលថ្លៃ៥ដុល្លារ សំរាប់អាយុ២១ឆ្នាំឡើងទៅ

**SATURDAY, March 14, 9AM-10:30AM:** Wildlife Tracking at Hawk Valley Farm on Varnum Avenue. RSVP by calling 978-934-0030.

មានការប្រកួតដេញសត្វព្រៃនៅ Hawk Valley Farm,Varnum Ave. សូមអញ្ជើញទូរស័ព្ទលេខ: ៩៧៨-៩៣៤-០០៣០

**11AM-4PM:** All-You-Can-Eat Chocolate Festival at St. Anne's Church, Admission $6 per Person ហូប"សូកូឡា"នៅវិហារ St. Anne លក់សំបុត្រចូល៦ដុល្លារម្នាក់

**12PM-3PM:** North Bowl Soup Competition at Club Celsius Tent. Tickets are $5 at the door, cash only, ប្រឡងធ្វើស៊ុបភាគខាងជើង នៅក្លឹប Celsius Tent, សំបុត្រមានលក់នៅទ្វារចូល ថ្លៃ៥ដុល្លារជាលុយសុទ្ធ ។

**12PM-4PM:** Horse-drawn Carriage Rides on Merrimack St. មានជិះរទេះសេះនៅផ្លូវ Merrimack

**12PM - 5PM:** Human Snowglobe Photo Station and, Ice Carving on JFK Plaza (at City Hall)

ថតរូបពិភពមនុស្សព្រិល -មានការឆ្លាក់ទឹកកកជុំនៅមណ្ឌលលក់ដូរJFKសាលាក្រុង)

**12PM - 5:30PM:** Mittens and Museum Madness Kids Play Area at Lowell High School សំរាប់កូនក្មេងលេងនៅសាលាមធ្យមសិក្សាឡូវែល ។

**2PM - 6PM:** Human Dog Sled Competition and Team Costume Contest on Arcand Drive, 6PM Be In A Giant Photo in Front of City Hall, ការប្រណាំងឆ្កែអូសរទេះលើទឹកកក និងប្រឡងសម្លៀកបំពាក់នៅផ្លូវ Arcand Drive, ម៉ោង៦ល្ងាច ថតរូបធំៗនៅមុខសាលាក្រុង ។

**7PM:** Multimedia Grand final with Pyrotechics and Ballon drop on JFK Plaza (at city Hall) សម្តែងសិល្បៈនៃការបាញ់កាំជ្រួចភាគបញ្ចប់ និងលេងល្បែងបោះបាល់ឡុងនៅមណ្ឌលលក់ដូរ JFK (សាលាក្រុង) ។

**7PM:** Middlenight: Live Music at Club Celsius Tent. Tickets are $5 at the door, cash only. Age 21+ only. ពីម៉ោង៧ដល់ពាក់កណ្តាលអធ្រាតមានចម្រៀង និងតន្ត្រីនៅក្លឹប Celsius Tent,- សំបុត្រមានលក់នៅទ្វារចូលថ្លៃ៥ដុល្លារសំរាប់អាយុ២១ឆ្នាំឡើងទៅ ។

**Lowell WinterFest is presented by the City of Lowell, the Greater Merrimack Valley Convention & Visitors Bureau, the Cultural Organization of Lowell, and the Merrimack Valley Chamber of Commerce.**

## តមកទំព័រទី ០៤ ដំណើរពីអាមេរិកទៅអាស៊ី...

តើអាលុចមានធនធានទប់ទល់ការនេះរួចឬទេ ? កាលពីកូនស្រីខ្ញុំរៀបការពីខែមុននោះ ក៏រៀបជាទំហំធំដូចគ្នាតែខ្ញុំបានដឹងពួកម្លាំងធនធានស្របនឹងបំណងរបស់គេ ដោយបានបូកសងលេខរួចជាស្រេច តែប៉ុណ្ណោះ រីឯខ្ញុំពុំបានជួយពួកគេអ្វីទេ ក្រៅតែពីមានវត្តមាននៅកន្លែងដែរពួកគេត្រូវការខ្ញុំជាឪពុកក្បែរពួកគេតែប៉ុណ្ណោះ ។

ខ្ញុំបានចាកចេញពីភ្នំពេញម៉ោង៧កន្លះមកដល់


សិល្បករ ព្រហ្ម ម៉ាញ និងនាង សារ៉ី នាំជំនូនមកជូនមេបារ

ដឹងច្បាស់ថា ខ្លួនគេនឹងទៅដល់ណា? គ្មានមន្ទិលទេ! រីឯកូនប្រុសមួយនេះ វាសនាវានៅនឹងដៃគ្រួសារខាងស្រីទាំងអស់ខ្ញុំគ្រាន់តែដឹងថា អាលុចវាបានលក់ឡានថ្មីមួយ ដើម្បីបង្គ្រប់លុយយកទៅការប្រពន្ធ

ព្រៃនគរម៉ោង៨ ខ្ញុំត្រូវចាំជើងយន្តហោះខ្ញុំ រហូតដល់ថ្ងៃស្អែកម៉ោង១០ព្រឹក តែយប់នោះមិនដឹងជាដេកពួនរបៀបណាទេ? ចំណតយន្តហោះ តាំងស៊ិនញ៉ើក មិនមានកន្លែង ឬបន្ទប់ឱ្យទេសចររង់ចាំទេ ដូច្នេះត្រូវតែអង្គុយរង់ចាំនៅក្បែរក្រុមអ្នកធ្វើការ "ត្រង់ស៊ីត" ដែលមនុស្សម្នាដើរកាត់មិនឈប់ដោយគ្មានទឹកផឹក ម្ហូបចំណី អ្វីទាំងអស់ លើកលែងតែបន្ទប់ទឹក មាននៅមិនឆ្ងាយពីទីនោះទេ ។ ចាំបាន១ម៉ោងមានអ្នកធ្វើការម្នាក់មកសួរថា សម្រាកបានស្រួល

ទៅទិញឱ្យបាន ខ្ញុំនៅមាន១ម៉ឺនដុង ចុងក្រោយ ក៏ហុចទៅឱ្យដោយចង់បាន"សង់វិច"មួយដុំនឹងទឹកមួយដប ហើយមិនបាច់យកលុយសល់មកឱ្យខ្ញុំទេ មួយស្របក់ក្រោយមកបុរសនោះក៏យកម្ហូបដែលខ្ញុំបញ្ជាទិញមកឱ្យធ្វើឱ្យខ្ញុំរីករាយច្រើនដោយម៉ោង១២ទៅហើយ នៅមិនទាន់បានអ្វីហូបនៅឡើយ ។ ហូបហើយសម្រាកបន្តិចដោយដេកកើយ "កាមេរ៉ា" នៅលើកៅអីរដេបរដុបដ៏រឹងកញ្ជឹសនោះទៅ ។ ម៉ោង២បន្តិចក្រោយមកស្រាប់តែមានខ្មែរ២នាក់ស្រីម្នាក់ប្រុសម្នាក់មកពីអាមេរិកដែរ តែត្រូវគេឃាត់មិនឱ្យបន្តដំណើរទៅភ្នំពេញដោយសារមិនបានចេញថ្លៃឥវ៉ាន់ដែលលើសគីឡូដូចគ្នាបានមកអង្គុយក្បែរខ្ញុំដេកទីនោះ ។ ដល់មានរឿងបីដូច១គ្នាអ៊ីចឹងធ្វើឱ្យខ្ញុំយល់ថា នេះជាល្បិចរកលុយដែលអ្នកទាំងពីរព្រួយបារម្ភថា កំពុងនៅក្នុងមាត់ខ្លាតែដាច់ណាត់ថា នឹងមិនឱ្យលុយជាដាច់ខាត ពីព្រោះតែឥវ៉ាន់ទាំងនោះគេបង់ថ្លៃដឹកជញ្ជូនរហូតទៅដល់ភ្នំពេញឯណោះរួចហើយ ។

ម៉ោង៨ព្រឹកឡើងខ្ញុំដឹងថា នាងស្រីម្នាក់នោះ បានចេញរួចទៅមុនដោយបានឡើងទៅជួបប្រធានក្រុម"ត្រង់ស៊ីត" រីឯបុរសនោះវិញ នៅរង់ចាំដំណោះស្រាយជាបន្តទៅទៀត ខ្ញុំក៏ចេញមកចាំជើងយន្តហោះម៉ោង១០ព្រឹករបស់ខ្ញុំដោយនឹកទៅដល់ពេល


ទទួលភ្ញៀវអ្នកចំរៀងឯក ព្រាប សុវត្ថិ មកចូលរួមមង្គលការ

ឬទេ? ខ្ញុំថា មិនស្រួលទេ! គេថា បើមិនស្រួលមានគេអាចចេញ"វីសារ"ឱ្យបានសម្រាប់ចេញទៅដេកនៅសណ្ឋាគារនៅក្បែរនេះ តែត្រូវចេញតម្លៃ២០០ដុល្លារ តម្លៃសណ្ឋាគារប្រមាណ៥០ក្នុង១យប់ ខ្ញុំតបថា ខ្ញុំគ្មានមធ្យោបាយនេះទេ! គេក៏ចេញទៅប្រមាណ១ម៉ោងមកទៀត មាននារីម្នាក់មកប្រាប់ខ្ញុំថា "ឥវ៉ាន់អ្នកឯងលើសទម្ងន់មិនអាចចេញពីទីនេះដោយមិនបង់លុយឱ្យគ្រប់គ្រាន់បានទេ" ខ្ញុំតបថា "ឥវ៉ាន់នេះមកពីស្រុកខ្មែរ គេបានថ្លឹងឥតមាននរណាប្រាប់ខ្ញុំពីរឿងនេះទេ ហេតុអ្វីក៏មានរឿងនេះកើតឡើងនៅទីនេះ?" គេថាខ្ញុំមានសិទ្ធតែ២០គីឡូទេ សម្រាប់ដាក់ឥវ៉ាន់លើយន្តហោះ ដូច្នេះត្រូវចេញថ្លៃផ្នែកដែលលើសនោះ! ខ្ញុំដឹងថា ឥវ៉ាន់ខ្ញុំគ្មានអ្វីសំខាន់ឱ្យលើស២០គីឡូទេ ហើយសម្រាប់ជើងទៅស.រ.អា ខ្ញុំអាចផ្ទុកបានលើសពីនេះថែមទៀត ខ្ញុំក៏តបថា "ខ្ញុំមិនមែនមកចុះនៅសាយគ្គូនទេ គឺខ្ញុំទៅស.រ.អា. បើមិនទទួលឥវ៉ាន់ខ្ញុំទេ គេនឹងប្រាប់ខ្ញុំតាំងពីដំបូងមិនមែននៅកណ្ដាលទីទេ ខ្ញុំមិនត្រូវចេញថ្លៃអីទៀតទេ"នាងតបថា "ខ្ញុំនឹងបញ្ជូនទៅយន្តហោះតាមលោកនិយាយបើយន្តហោះមិនទទួលកុំថា ខ្ញុំមិនបានប្រាប់" ខ្ញុំក៏ប្រញាប់យល់ព្រម បន្ទាប់ពីរើឥវ៉ាន់មានកុំព្យូទ័រ មានកាមេរាធំតូចនៅជាមួយរយើងរយោង ដើម្បីរកឯកសារនិយាយពីឥវ៉ាន់នៅមុខនាងនោះមក។ ទៅបាត់មួយសន្ទុះមានអ្នកធ្វើការម្នាក់ទៀតមកសួរថា បើអ្នកចង់បានអីហូបខ្ញុំអាច

ចូលទៅ"បាយឆៅ"កាលពី១០ថ្ងៃមុននោះ យើងមិនហ៊ានយក"កាមេរ៉ា"ធំនឹងកុំព្យូទ័រធំប្រើសម្រាប់កាសែតទៅក្នុងប្រទេសយួនទេ ពួកនោះមិនសូវចូលចិត្តអ្នកកាសែតទេ ហើយក៏ប្រើច្បាប់ចង្អៀតចង្អល់មិនដូចគ្នានឹងប្រទេសសេរីផងដែរ ។ នៅបាយឆៅយើងប្រើកាមេរ៉ាតូច១នឹងទិញកុំព្យូទ័រតូចគ្មានឯកសារអ្វីទាំងអស់យកទៅជាមួយទេ ។ នៅបាយឆៅជាក្រុងតូចមួយខ្ញុំសរសេរអត្ថបទកាសែតមួយហើយបញ្ចូលទៅក្នុង"ផ្លស់ជ្រាយ" ហើយយកទៅផ្ញើរនៅទីក្រុងឆ្ងាយពីផ្ទះ ហាក់ដូចជាមានសន្តិសុខពីការស្រាវជ្រាវរបស់ប៉ូលីសយួនជាងយើងបារម្ភមែនតែឥតមានបញ្ហាអ្វីកើតឡើងនោះទេ។

នៅក្នុងយន្តហោះទៅហុងកុងខ្ញុំផ្ដើមសម្រាកបានខ្លះដោយយប់ពីម្សិលនោះ ខ្ញុំពុំបានដេកពួនទេ ខ្ញុំដឹងថា ទៅដល់សម្រាកនៅហុងកុង៣ថ្ងៃ ទើបបន្តដំណើររទៅអាមេរិកទៀត នៅទីនោះ របៀបទទួលភ្ញៀវ ទោះជាចូលជារបបកុម្មុយនិស្តចិនទៅហើយក្ដី ក៏នៅមានកុងត្រាអន្តរជាតិជាមួយចក្រភពអង់គ្លេសថានៅរក្សាច្បាប់ទម្លាប់ជាសេរីចំនួន៥០ឆ្នាំបន្តទៅទៀត មុននឹងអាចកែរប្រែជាអ្វីដែលរដ្ឋអំណាចថ្មីចង់ទៅបាន ដូច្នេះខ្ញុំអាចមានអារម្មណ៍ រួចពីគុកបាន។

**លេខក្រោយយើងនឹងនិយាយពីហុងកុងជូនជាសណ្ដាប់ជាបន្តទៅទៀត។**


គណបក្សសង្គ្រោះជាតិ
Cambodia National Rescue Party
សង្គ្រោះ បម្រើ ការពារ Rescue Serve Protect

សេចក្ដីជូនដំណឹង និង លិខិតអញ្ជើញ



សាខាគណបក្សសង្គ្រោះជាតិប្រចាំរដ្ឋនានា ក្នុងសហរដ្ឋអាមេរិក មានកិត្តិយសសូមជម្រាបជូនដល់សាធារណៈជន ឱ្យបានជ្រាបថា **ឯ.ឧ. កឹម សុខា អនុប្រធានគណៈបក្សសង្គ្រោះជាតិ** និងជា **អនុប្រធានទីមួយនៃរដ្ឋសភាកម្ពុជា** និង **ឯ.ឧ. ម៉ៅ គឹម ជាង តំណាងរាស្ត្រខេត្តកំពង់ឆ្នាំង** នឹងធ្វើដំណើរទស្សនៈកិច្ចរួមគ្នានៅតាមបណ្ដារដ្ឋនានាចាប់ពីថ្ងៃសុក្រទី១៣ ខែមិនា ឆ្នាំ២០១៥ ដល់ថ្ងៃអាទិត្យទី២២ ខែមិនា ឆ្នាំ២០១៥។ សេចក្ដីជូនដំណឹងនេះចាត់ទុកជាការអញ្ជើញដល់បងប្អូនជនរួមជាតិ និងអន្តរជាតិ ចូលរួមឱ្យបានច្រើនកុះករ។ សម្រាប់ព័ត៌មានលម្អិត សូមទាក់ទងតំណាងរបស់**គណបក្សសង្គ្រោះជាតិ តាមបណ្ដារដ្ឋនានា** ដូចខាងក្រោម ឬទាក់ទងមកអ្នកសម្របសម្រួលទស្សនៈកិច្ច **គឺលោក ផាន ប្រាក់ (Mr. Phan Prak):** (325)2626145។ សូមអរគុណ!!!

| STATE - រដ្ឋ | DATE - កាលបរិច្ឆេទ | CONTACT - អ្នកទាក់ទង | PHONE # - ទូរស័ព្ទ |
|---|---|---|---|
| California (Northern & Southern) | March 13 – 14, 2015 | Mr. Sam Vanthana (Northern, CA)<br>Mr. Khorng Pe (Southern, CA)<br>Mr. Suon In (Northern, CA) | 209-609-1409<br>323-633-4182<br>510-409-9937 |
| Washington State | March 15 – 16, 2015 | Mr. Channdara Sos<br>Mr. Hoeun Voeuk | 206-850-7565<br>253-266-2100 |
| Tennessee | March 16 – 17, 2015 | Mr. Pov Touch | 901-279-9197 |
| Washington, DC | March 18 – 19, 2015 | Mr. Vibol Touch<br>Mr. Saunora Prom | 703-350-7911<br>703-802-4750 |
| Philadelphia, Pa | March 20, 2015 | Mr. Samon Var<br>Mr. Chea Meas | 215-410-2574<br>215-833-3669 |
| Massachusetts | March 21, 2015 | Mr. Synoun Kham<br>Mr. Peng An Tan<br>Mr. Rithy Uong | 603-689-4204<br>978-677-0654<br>978-996-6969 |
| Texas | March 22, 2015 | Mr. Phan Prak | 325-262-6145 |

Organized by: CNRP USA

## តមកទំព័រទី ០៣ The School for Field Studies (SFS) បាន...

កម្មវិធី "The Living Mekong ការអភិរក្ស ទឹក និងការអភិវឌ្ឍន៍ក្នុងបរិយាកាសប្រែប្រួល" ត្រូវបានណែនាំ កាលពីខែកញ្ញាថា ជាកម្មវិធីសិក្សាក្រៅប្រទេសផ្នែកបរិស្ថានរយៈពេលមួយឆមាសដែលមានមូលដ្ឋាននៅខេត្តសៀមរាប។ កម្មវិធីសិក្សាដែលអាស្រ័យលើការស្រាវជ្រាវដល់ទីកន្លែងដ៏ប្លែកជាងគេនេះ សិក្សាអំពីសារៈសំខាន់នៃទន្លេមេគង្គដែលជាប្រភពនៃការប្រកបរបរចិញ្ចឹមជីវិតសម្រាប់ប្រជាជនរាប់លាននាក់ ។ The Living Mekong នេះមានបង្រៀនទាំងក្នុងឆមាសរដូវឈើជ្រុះស្លឹក និងនិទាឃរដូវជារៀងរាល់ឆ្នាំ ហើយផ្តល់ឱកាសដល់និស្សិតបរិញ្ញាប័ត្រសហការជាមួយនឹងមហាវិទ្យាល័យ SFS ធ្វើការស្រាវជ្រាវសំខាន់ៗផ្នែកបរិស្ថានទាក់ទងនឹងផលប៉ះពាល់នៃបម្រែបម្រួលបរិយាកាស នគរូបនីយកម្ម និងកសិកម្មទៅលើប្រព័ន្ធអេកូ-សាស្ត្រក្នុងតំបន់ទន្លេមេគង្គ។ និស្សិតនឹងសិក្សារយៈពេល១៨ម៉ោងក្នុងមួយឆមាស។ មុនបញ្ចប់វគ្គសិក្សានេះ និស្សិតត្រូវបង្កើតគម្រោងស្រាវជ្រាវចុះស្រាវជ្រាវដល់ទីកន្លែង និងធ្វើបទបង្ហាញពីលទ្ធផលស្រាវជ្រាវរបស់ពួកគេដល់សហគមន៍មូលដ្ឋានក្នុងតំបន់។

ប្រសិនបើអ្នកចង់ដឹងព័តិមានបន្ថែមអំពីកម្មវិធីក្រៅប្រទេសរយៈពេលមួយឆមាស The Living Mekong សូមចូលទៅគេហទំព័រ http://www.fieldstudies.org/mekong ។

ប្រសិនបើអ្នកចង់ដឹងព័តិមានបន្ថែមអំពីអាហារូបករណ៍បេតិកភណ្ឌ SFS សូមចូលទៅ





គេហទំព័រ http://www.fieldstudies.org/admissions/aid ឬផ្ញើរអ៊ីម៉ែលទៅ admissions@fieldstudies.org ។

ព័តិមានអំពី The School for Field Studies.

អស់រយៈពេលជាង៣០ឆ្នាំមកហើយ The School for Field Studies ដែលជាកម្មវិធីសិក្សាក្រៅប្រទេសផ្នែកបរិស្ថានសម្រាប់និស្សិតបរិញ្ញាប័ត្រដ៏ធំជាងគេបំផុតក្នុងសហរដ្ឋអាមេរិក បានរួមបញ្ចូលការសិក្សាផ្នែកបរិស្ថានចម្រុះផ្ទាល់ជាមួយនឹងការស្រាវជ្រាវផ្នែកវិទ្យាសាស្ត្រ ដើម្បីស្វែងរកវិធីដោះស្រាយបញ្ហាបរិស្ថានធ្ងន់ធ្ងរតាមបែបស្វ័យទ្រទ្រង់។ និស្សិត SFS សហការជាមួយសហគមន៍មូលដ្ឋាន ដើម្បីស្វែងរកវិធីជាក់ស្តែងពិតប្រាកដសម្រាប់ការគ្រប់គ្រងធនធានធម្មជាតិរបស់ពួកគេ និងឆ្លងកាត់ការផ្លាស់ប្តូរបទពិសោធន៍ដែលនឹងជួយឱ្យវិជ្ជាជីវៈរបស់ពួកគេមានការរីកលូតលាស់ និងធ្វើឱ្យពួកគេយល់ដឹងពីសកលលោក។ សូមចូលមើលគេហទំព័រ www.fieldstudies.org .

សូមទាក់ទង Leslie Granese, The School for Field Studies តាមរយៈលេខទូរស័ព្ទ ៖ ៩៧៨-២១៩-៥១២០ និងអ៊ីម៉ែល lgranese@fieldstudies.org





តមកពីទំព័រទី ០១ នយោបាយទប់ការបង្ហូរឈាមខ្មែរ...

លោក ហ៊ុន សែន ទេ ដែលនៅជំទាស់ទាមទារលក្ខខណ្ឌថ្មីបន្ថែមក្រោយកិច្ចចរចាផ្លូវការណ៍ តើមានអ្វីកើតឡើង?

លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ផ្តើមធ្វើសង្គ្រាមទឹកមាត់សាជាថ្មីថា"កងទ័ពនឹងមានកំហឹងខ្លាំង ប្រសិនបើមានបាតុកម្មថ្មីម្តងទៀត" នឹងបន្ថែមគម្រាមថា "នឹងគ្មានគ.ជ.ប.ថ្មីទេ បើគ្មានច្បាប់និយាយថា"គ.ជ.ប.អាចដកអាសនៈពីអ្នកជាប់ឆ្នោតធ្វើពហិការទៅឱ្យអ្នកផ្សេងបាន..." នេះបន្ទាប់ពីបានប្រញាប់បញ្ចូលមេទាហ៊ាន នឹងមេប៉ូលិសច្រើនរូបក្នុងគណកម្មការនាយកគណបក្សប្រជាជនរួចមក ។ គណកម្មកានាយករបៀបនេះមានន័យថា មានការពង្រឹងកងប្រដាប់អាវុធឱ្យនៅក្រោមបង្គាប់នៃគណបក្សប្រជាជនឱ្យតែរឹតតែមាំក្នុងខណៈដែលលោក ហ៊ុន សែន ឡើងជាប្រធានស្តីទីជំនួសលោក ជា ស៊ីម ទ្រុឌទ្រោមដោយជម្ងឺប្រចាំកាយ ។ តើព្រឹត្តិការណ៍នេះបានន័យយ៉ាងណា ?

**១-**បើសភាពេញអង្គនៅខែឧសភាអនុម័តច្បាប់ទាំងមូល ដូចសេចក្តីព្រាងនៃកិច្ចចរចាបានន័យថា សភាជាតិបានបង្ហាញជាលើកដំបូង "មិននៅក្រោមបញ្ជានាយករដ្ឋមន្ត្រីទេ" ហើយក៏បានន័យដែរថា គណបក្សប្រជាជនពេលនេះមិនចុះសម្រុងគ្នាជាមួយ ហ៊ុន សែន ដូចមុនទេ

**២-**បើសភាដដែលនេះ អនុម័តច្បាប់មានមាត្រាបន្ថែមតាមបំណងថ្មីរបស់លោក ហ៊ុន សែន បានន័យថា គណបក្សប្រជាជននៅក្នុងកណ្តាប់ដៃលោក ហ៊ុន សែន ដដែល ហើយក៏បានន័យដែរថា គណបក្សប្រជាជនពុំមានឆន្ទៈគោរពកិច្ចព្រមព្រៀងថ្ងៃ២២កក្កដាមុននោះទេ។

គណបក្សសង្គ្រោះជាតិនៅពេលដែលដឹកនាំកម្លាំងប្រជាពលរដ្ឋធ្វើបាតុកម្មឡើងដល់កំពូលប្រឆាំងនឹងរដ្ឋាភិបាលនាចុងឆ្នាំ២០១៣ ដោយចង្អុលចំមុខថា គណបក្សប្រជាជនបានលួចសន្លឹកឆ្នោតរបស់ខ្លួន រួចហើយក៏ស្រាប់តែបញ្ឈប់



លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន គំរាមគ្មានប្រណីមាត់

បាតុកម្មនោះទៅវិញជាបន្ទាន់សុខចិត្តទទួលយកអាសនៈទាំង៥៥ជាលទ្ធផលនៃការបោះឆ្នោតឆ្នាំ២០១៣ដែលរដ្ឋាភិបាលប្រកាសជំនួស គ.ជ.ប.។ នេះគឺជាការធ្វើសម្បទានឱ្យគណបក្សប្រជាជនដោយដាក់លក្ខខណ្ឌតែមួយគត់ គឺ "ទម្លាក់គណកម្មាធិការជាតិរៀបចំការបោះឆ្នោតហៅកាត់ថា គ.ជ.ប.ចាស់ចោលហើយរៀបចំគ.ជ.ប.មួយថ្មីក្នុងច្បាប់ថ្មីរបស់ប្រទេស"ដោយសុខចិត្តចាំការបោះឆ្នោតឆ្នាំ២០១៨ប្រកបដោយសុច្ចរឹតយុត្តិធម៌មួយនឹងកើតឡើង ។ នៅពេលជាមួយគ្នានោះ លោក ហ៊ុន សែន នឹងលោក ទា បាញ់ រដ្ឋមន្ត្រីខាងយោធាខកខានមិនបានបង្ក្រាបបាតុកម្មដ៏ធំសម្បើមដោយយោធាម្តងហើយ អន្ទាក់ទី១របស់ ហ៊ុន សែន បានត្រូវលោតកន្លងរួច ។

ឥឡូវជិតដល់ចុងបញ្ចប់នៃការចរចាបង្កើតបានគ.ជ.ប.ថ្មីបានស្រាប់តែមានព្រឹត្តិការណ៍បើកចំហរតួនាទីប្រធានគណបក្សប្រជាជន គឺលោក ជា ស៊ីម មានជម្ងឺជាទម្ងន់អាចនឹងបាត់បង់ជីវិតទៀតផង តើនរណានឹងក្លាយជាប្រធានបក្ស? លោក ហ៊ុន សែន ឬក៏លោក ស ខេង ? ភាពស្រពេចស្រពិលដែលកំពុងកើតនៅក្នុងសភាជាតិអាចជាសញ្ញានៃការប្រទាញប្រទង់យកដំណែងប្រធាននោះផងដែរ ។ បើព្រឹត្តិការណ៍ទី១ នឹងកើតឡើងអំណាចនៅសភានឹងប្តូរដៃពី ហ៊ុន សែន ចេញហើយៗក៏អាចជាការប្រេះឆាផ្ទៃក្នុងគណបក្សប្រជាជនមួយយ៉ាងសំខាន់មួយដែលការបែកបាក់ក្នុងរបបកុម្មុយនីស្តជាច្រើន គឺសង្គ្រាមដណ្តើមអំណាច។ តែបើព្រឹត្តិការណ៍ទី២ កើតទៅវិញ គេនឹងពុំឃើញមានការបោះឆ្នោតដោយសេរីនឹងយុត្តិធម៌កើតឡើងបានទេ។

លោក ហ៊ុន សែន នៅពេលបញ្ចេញលក្ខខណ្ឌថ្មី គឺជាអន្ទាក់ទី២ ដែលអាចបានន័យថា កិច្ចចរចានឹងគាំងដំណើរគ.ជ.ប.ចាស់ដែលម៉ាស៊ីនបោះឆ្នោតរបស់គណបក្សប្រជាជននៅបន្តដឹកនាំការបោះឆ្នោត នាឆ្នាំខាងមុខតទៅទៀត។ ការខិតខំកាពារយ៉ាងស្វិតស្វាញរបស់ ហ៊ុន សែន ចំពោះគ.ជ.ប.ចាស់រឹតតែបង្ហាញថាគ.ជ.ប.នោះបំរើលោកបានល្អណាស់តើគណបក្សសង្គ្រោះជាតិនឹងលោតអន្ទាក់ទី២ នៅឆ្នាំ២០១៧-១៨ថ្មីនេះរួចរបៀបណា?

ក៏ប៉ុន្តែការវិភាគខាងលើនេះនៅខ្វះកត្តាប្រជាពលរដ្ឋទាំងស្រី ទាំងប្រុស ទាំងយុវជនដែលឈប់ខ្លាចរអែងអំណាចកាំភ្លើងដំបងឆក់ឬការជាប់គុគ របស់អាជ្ញាធរ ប៉ូលិស-ទាហ៊ានតុលាការ អ្វីទាំងអស់ទៅហើយ នេះជាកម្លាំងដ៏ធំធេងមិនចេះរីងស្ងួតដែលនៅជាដង្ហៀបលើគណបក្សប្រជាជនរួចជាស្រេច ។ រីឯគណបក្សសង្គ្រោះជាតិ បើទោះជាមានការខិតខំវាយប្រហារពីគណបក្សប្រជាជនពីបញ្ញាវន្តឯករាជ្យខ្លះៗ ឬពីអ្នកមានសម្បត្តិក្នុងស្រុក ឬគ៏បរាជ័យក្នុងការចរចារសន្តិវិធីក៏ដោយនៅតែជាកម្លាំងក្បាលម៉ាស៊ីនដែលបានស្ម័គ្រចិត្តត្រៀមបំរើយ៉ាងស្មោះត្រង់នៅឡើយ ចំពោះប្រជាពលរដ្ឋដែលរងគ្រោះពីរបប ហ៊ុន សែន ។ ក្បាលដងខ្លួន នឹងកន្ទុយអាចនឹងតភ្ជាប់គ្នាបានយ៉ាងឆាប់រហ័សនៅពេលដែលលោក ហ៊ុន សែន ផ្តើមដុតក្តីសង្ឃឹមរបស់ពួកគេចោលយ៉ាងផ្តើនធ្វើឱ្យឈឺចាប់ទ្រាំលែងបាន។

ប្រជាពលរដ្ឋប្រមាណ១លាននាក់ដែលបានផ្តល់ការគាំទ្រដល់មេដឹកនាំគណបក្សប្រឆាំងមាន សម រង្ស៊ី និង កឹម សុខា ឥតបានភ័ន្តច្រឡំ ឬចាក់ខុសនោះទេទោះជានៅពេលដែលគណបក្សសង្គ្រោះជាតិចូលសភាក៏ដោយ ពីព្រោះគណបក្សនេះបន្តតស៊ូទន្ទឹមស្មានឹងពលរដ្ឋដដែលតែនៅលើសមរភូមិផ្លូវខុសគ្នា គឺពីក្នុងអំណាចរដ្ឋតែប៉ុណ្ណោះ ។ ទៅអនាគតស្មាដៃដែលធ្លាប់បានធ្វើឱ្យកៅអីអំណាចផ្តាច់ការរង្គោះរង្គើគួរឱ្យរន្ធត់បានម្តងហើយ ចរន្តនោះនៅមានពិសខ្លាំងក្លានៅឡើយ ហេតុនេះ ហើយបាន ហ៊ុន សែន បារម្ភហើយរិះរកមធ្យោបាយទប់ទល់ខ្លាំងណាស់មិនបានឈប់សោះនោះ ៕

ហ៊ុន សែន អស់ប្រជាប្រិយដោយការពារគណបក្សប្រជាជនមិនបាន ដូច្នេះនឹងអស់អំណាចស្របពេលជាមួយគ្នានេះពាក្យបណ្តឹងចំពោះឈ្មោះ ហ៊ុន សែន ផ្ទាល់ ស្តីពី ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក៏កំពុងចូលទៅកាន់តុលាការអន្តរជាតិនៅភ្នំពេញ ECCC បន្ថែមទៀត ៕



# កម្មវិធីផ្សេងៗនៅក្នុងក្រុង

## ១_ពិធីបុណ្យរដូវត្រជាក់នៅក្រុងឡូវែលឆ្នាំ ២០១៥ (Lowell Winterfest 2015)

**ថ្ងៃសុក្រ ទី១៣ និងថ្ងៃសៅរ៍ ទី១៤ ខែមីនា ឆ្នាំ ២០១៥**

**http://lowell.org/Pages/Winterfest.aspx**

នៅថ្ងៃចុងសប្តាហ៍ក្រោយថ្ងៃទី១៣ និង ១៤ ខែមីនា សូមអញ្ជើញមកចូលរួមឱ្យបានច្រើន



កុះករនៅតាមដងផ្លូវកណ្តាលទីក្រុងឡូវែលដែលយើងរៀបចំឱ្យក្លាយទៅជាឋានមនោរម្យនារដូវត្រជាក់នេះ។ យើងប្រារព្ធពិធីបុណ្យរដូវត្រជាក់ប្រចាំឆ្នាំរបស់ទីក្រុងឡូវែលលើកទី១៥! នៅក្នុងពិធីបុណ្យនេះ យើងមានរៀបចំកម្មវិធីសប្បាយប្លែកៗ។ លោកអ្នកអាចក្រេបស្រាបៀររបស់ក្រុមហ៊ុនស្រាបៀរអាមេរិក Mircobrew ក្នុងកម្មវិធីប្រកួតគុណភាពស្រាបៀរអាមេរិក ឬ Microbrew Competition និងពិសារសម្លក្តៅៗដែលនាំមកពីភោជនីយដ្ឋានផ្សេងៗក្នុងកម្មវិធីប្រកួតគុណភាពសម្ល North Bowl soup competition និងកុំភ្លេចទស្សនាកម្មវិធីជិះគាវទឹកកកអូសដោយមនុស្ស! សូមនាំក្រុមគ្រួសារមកទាំងអស់គ្នា ដើម្បីចូលរួមសប្បាយក្នុងកម្មវិធីសម្រាប់ក្មេងៗមានដូចជាស្តង់សម្រាប់ផ្តល់ភេសជ្ជៈសូកូឡាក្តៅៗតាមចំណូលចិត្តកន្លែងអាំងសាច់ចង្កាក់ស្តង់អាហារលើរថយន្តពិធីញាំុសូកូឡាគ្រប់មុខពិធីសម្តែងព្រួសភ្លើងដោយក្រុម Cirque de Light និងកម្មវិធីជាច្រើនមុខទៀត។ កុំភ្លេចយកម៉ាស៊ីនថតរូបមកផង។ ក្នុងឆ្នាំនេះយើងមានកម្មវិធីថ្មីមួយ គឺកម្មវិធីថតរូប ជុំគ្រួសារក្នុងកន្លែងតាំងព្រិលដើម្បីរម្លឹកអនុស្សាវរីយ៍រដូវត្រជាក់។ ក្នុងពិធីបុណ្យឆ្នាំនេះ យើងអញ្ជើញក្រុមសិល្បៈករល្បីៗដែលបានទទួលរង្វាន់ផ្នែកតន្ត្រីពីកម្មវិធី New England Music Awards មកចូល រួមសម្តែងតន្ត្រីផ្ទាល់។ ដូច្នេះសូមកុំភ្លេចចូលរួមស្តាប់តន្ត្រីកំសាន្តនៅ Club Celsius នៅរាត្រីនោះផងដែរ !

សូមអញ្ជើញចេញមកចូលរួមទាំងអស់គ្នាឱ្យបានច្រើនកុះករ ដើម្បីអបអរពិធីបុណ្យរដូវត្រជាក់ប្រចាំឆ្នាំរបស់ទីក្រុងឡូវែលយើងដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី១៣ និង១៤ ខែមីនាខាងមុខនេះ នៅតំបន់កណ្តាលក្រុងឡូវែល! សូមអានកម្មវិធីលម្អិតនៅលើគេហទំព័រ

http://lowell.org/Pages/Winterfest.aspx.

## ២_ក្រុមវាយកូនគោលលើទឹកកក UMass Lowellhockey Team នឹងរៀបចំកម្មវិធីប្រកួតជម្រុះបួនក្រុមចុងក្រោយ : The Hockey East Quarterfinals



នៅថ្ងៃទី១៣-១៥ ខែមីនា នៅមជ្ឈមណ្ឌល Tsongas Center តទៅទំព័រទី ១៣

# Local Events

**Friday March 13th & Saturday March 14th 2015**
**http://lowell.org/Pages/Winterfest.aspx**

## 1-Lowell Winterfest 2015

Join us next weekend, March 13th and 14th, as Downtown Lowell transforms into a Winter Wonderland for the 15th annual Lowell Winterfest! During the City's Winterfest Celebration, enjoy live entertainment while sipping on local Mircobrew's during the 3rd annual Microbrew Competition, warm up with some soup as local restaurants go head to head to take home prizes for the best soup at the North Bowl soup competition, and let's not forget the coveted human dog sled races! Bring the whole family and enjoy the many children's activities planned including a custom hot chocolate bar, fire pits to roast marshmallows, food trucks, an all-you-can-eat chocolate festival, live fire shows by Cirque de Light and more! Don't forget the camera at home- new this year is the Human Snow globe photo station to capture your families' memories from Winterfest. This year Winterfest will be partnering with a handful of New England Music Awards winners to bring you some of the best live, local music in New England, so be sure to end your evenings at Club Celsius to take in the tunes!

So come out and celebrate the season on March 13th and 14th at Lowell Winterfest in Downtown Lowell! To view the complete Schedule of Events visit http://lowell.org/Pages/Winterfest.aspx.

**2-The UMass Lowell hockey team will host the Hockey East Quarterfinals** : March 13-15 at the Tsongas Center in Lowell, MA. The River Hawks finished the regular season with a record of 18-10-6 and are looking to defend their Hockey East Tournament Championship, which they won in 2013 & 2014. Heading into the playoffs as the 4th seed in Hockey East, UMass Lowell will play a best-of-three series on home ice beginning Friday, March 13 at 7:15pm. Tickets are on sale now online and at the Tsongas Center Box Office, mention the Greater Merrimack Valley CVB and receive a 20% discount on tickets.

**3-Mill City Grows will host Lowell's first Urban Growers Gathering** :

on Saturday, March 21st, from 11am-3pmat Middlesex Community College, Lowell Campus.The event will help area gardeners get a jump start on the growing season with a day of workshops, demonstrations, seed swapping, film screening, local food sampling and more. Attendees can join workshops on composting, rooftop gardening, seed-saving, healthy cooking, organic pest management, and even garden-centered martial arts! Local youth leaders will share tips on how to get involved and make a difference, from making DIY natural body and beauty care products, to building a DIY drifter to observe ocean and watershed currents. Keynote speaker Mareleen Manos-Jones will make a presentation about the importance of native pollinator species, like the Monarch butterfly, and what we can do in our own gardens to support and attract these beautiful creatures.

For more information please visit www.millcitygrows.org



# តម្លៃផ្ទះកំពុងឡើងថ្លៃ

**ពីរីឆើត ភី. ហូវ ចេអ.**

**ប្រែសម្រួលដោយៈ ថាច់ វណ្ណា**

តម្លៃផ្ទះនៅឡូវែលកំពុងឡើងសន្សឹមៗហើយ ។ នេះគឺមានមូលហេតុមួយចំនួនៈ,

**ទី១ៈ** ដោយមានផ្ទះចំនួនតិចដែលបានដាក់លក់ បើមានផ្ទះដាក់ទីផ្សារ គឺលក់ចេញយ៉ាងឆាប់រហ័ស, ជាញយដងគេលក់បាននូវតម្លៃដែលចង់បាន ឬក៏បានច្រើនជាង,

**ទី២ៈ** មូលហេតុមួយទៀត ព្រោះធនាគារបើកឱ្យខ្ចីប្រាក់ដែលការប្រាក់មានអត្រានៅទាបនៅឡើយដែលអ្នកទិញផ្ទះអាចខ្ចីបាន (នឹងផ្តល់ឱ្យ) លុយច្រើនផង ។

មានផ្ទះភាគច្រើនដែលបានចាប់ផ្តើមដាក់លក់ គឺជាម្ចាស់ផ្ទះនៅផ្ទះនោះខ្លួនឯងអស់ជាង២០ឆ្នាំហើយ, បានន័យថាៈ ចាស់ៗដាក់លក់ផ្ទះប្រចាំគ្រួសាររបស់គាត់ ដើម្បីទៅប្តូរយកផ្ទះ "ខុងដ" តូចជាង ឬក៏ផ្ទះឯកទេសសម្រាប់ជួយជីវភាពមនុស្ស, ឬទៅរកផ្ទះថ្មីនៅដំបន់ក្តៅដូចរដ្ឋផ្លរីដាជាដើម ។

**ទី៣ៈ** មានមូលហេតុមួយទៀត, ចំពោះប្រជារាស្ត្រមានវ័យកណ្តាលពួកគេមិនព្រមលក់ផ្ទះរបស់ ពួកគេក្នុងគ្រាឥឡូវនេះឡើយ, ព្រោះពេលដែលពួកគេទិញផ្ទះនោះក្នុងអំឡុង




ឆ្នាំ២០០៤ដល់ឆ្នាំ២០០៧ផ្ទះមានតម្លៃខ្ពស់

**តទៅទំព័រទី ១១**

# Home Values Increasing

**By Richard P. Howe Jr.**

The values of homes in Lowell are slowly increasing. There are several causes for this. First, there is a lack of homes that are for sale so those that do go on the market sell quickly, often for the asking price or more. Another reason for increasing values is that interest rates are still low which allows home buyers to borrow (and offer) more money.

Most of the houses now begin offered for sale have been owned for more than twenty years by the same people. This means that older people are selling their family homes in exchange for smaller condominiums, assisted living facilities, or even new homes in Florida or other warmer places.

One reason more middle aged people are not selling their houses now is that many bought their homes when values **Continued to page 11**

SAVINGS WITH MASS APPEAL




**Want to save on car insurance? Call me first.**

It's time Massachusetts drivers had a better car insurance experience. I'll help you get the coverage that's right for you and the discounts you deserve. Call me today.



**Vanessa Dinh**
**781-547-6522**
665 Main Street
Waltham
vanessadinh@allstate.com

Allstate. You're in good hands.

Savings based on national customer-reported data for new policies in 2012. Actual savings vary. Allstate Insurance Co. Northbrook, IL. © 2013 Allstate Insurance Co.



Lowell Housing Authority Wellness Fair

Saturday, March 28th from 9:00am-12:00pm at the Mercier Center

**អាជ្ញាធរលំនៅដ្ឋានក្រុងឡូវែលពិព័រណ៍សុខុមាលភាព**

សូមអញ្ជើញចូលរួមនៅថ្ងៃសៅរ៍ទី២៨ខែមិនា,ម៉ោង៩-១២ថ្ងៃត្រង់នៅមណ្ឌល មើស៊ីយើ (Mercier Center)សម្រាប់សុខុមាលភាពបាន១ថ្ងៃយើងខ្ញុំមានព័ត៌មាននឹងរបស់ផ្សេងៗជូនដល់គ្រួសារអ្នកដោយឥតគិតថ្លៃ!

**សកម្មភាពរួមមាន :**

| | | |
|---|---|---|
| ជ្រើសសម្រាំងសុខភាព | តារាងសិក្សា | សកម្មភាពសម្មាប់កូនក្មេង |
| សម្ពាធឈាម | សុខភាពតួទ្រូង | បោះផង់សណ្តែក |
| សន្ទះដុំសាច | សុខភាពបេះដូង | ល្បែងលាងដៃ |
| មហារីកស្បែក | ជម្ងឺហឺត | និងល្បែងផ្សេងទៀត |
| មហារីកមាត់ | ឈប់ឬ ផ្អាកជក់បារី | ជាច្រើន... |

អ្នកចូលរួម២០០គ្រួសារមុនដំបូងបង្អស់ និងបានទទួលអំណោយកាត២៥ដុល្លារពី (Market Basket) ម៉ាកឃិតបាស្កិត និងមានលក់ឆ្នោត,កៅអីធ្វើសរសៃ,ផ្តល់យោបល់ពីការតុបតែង និងតុបតែងសាថ្មីដោយឥតគិតថ្លៃព័ត៌មានបន្ថែមសូមអញ្ជើញទាក់ទងមក: (Heather Hilbert)

ទូរស័ព្ទលេខ: **978-788-7078**

Lowell General Hospital
Complete connected care™

តមកពីទំព័រទី ១០ **តម្លៃផ្ទះកំពុងឡើងថ្លៃ...**

រួចត្រូវជំពាក់លុយរំលួសច្រើនជាងតម្លៃផ្ទះថ្មីដែលដាក់លក់សព្វថ្ងៃទៅទៀត, ធ្វើឱ្យផ្ទះនោះលក់មិនបានអាមេរិកាំងហៅថា : (being underwater) ទឹក ដល់ច្រមុះ ។ ប្រជារាស្ត្រណាដែលស្ថិតនៅក្នុងស្ថានភាពបែបនេះ, ពុំអាចលក់ផ្ទះរបស់ខ្លួនបានឡើយ, ព្រោះវាមិនគ្រប់លុយយកទៅសងលុយខ្ចីទិញផ្ទះឡើយ ។

តារាងកំណត់ថ្លៃផ្ទះបង្ហាញតម្លៃដែលបានចុះក្នុងបញ្ជី "ឌីត" កត់ត្រាពីផ្ទះកម្មសិទ្ធនៅឡូវែលសម្រាប់ឆ្នាំ២000 រហូតដល់ឆ្នាំ ២០១៤, បានបង្ហាញឱ្យឃើញភាគរយនៃតម្លៃឡើងចុះពីមួយឆ្នាំទៅមួយឆ្នាំ, ឧទាហរណ៏: តម្លៃមធ្យមឆ្នាំ២00៣ ថ្លៃ:$២១៧.000 នោះគឺមានចំនួន១៦%ឡើងថ្លៃជាងឆ្នាំ ២00២ ដែលមានតម្លៃមធ្យម$១៨៧,៣៧៥ប៉ុណ្ណោះ ។ ពេលនេះជាដំណឹងល្អមួយសម្រាប់អ្នកទិញផ្ទះពីឆ្នាំ២000មក,តម្លៃផ្ទះត្រូវឡើងទៅដល់៤៩%តាំងពីពេលនោះមក ៕




Continued from page 10

## Home Values Increasing..

were highest which was between 2004 and 2007. Because many who bought during that time borrowed all or nearly all of the purchase price, they still owe more money on their mortgages than their homes are now worth. This is called “being underwater.” People in this situation often cannot sell their homes because they will not get enough money from the sale to pay off their mortgage.

The table below shows the median price on deeds recorded for property in Lowell for each year from 2000 to 2014. The table also shows the percentage that each year’s price changed from the year before. For example, the median price in 2003 was $217,000 which was a 16% increase from 2002 when the median price was just $187,375. The good news is that if you purchased your house in 2000, its value has increased 49% since then.

| ឆ្នាំYear | តម្លៃមធ្យម Median price | តម្លៃកើនចុះ:Change prior year |
|---|---|---|
| 2000 | $140,000 | |
| 2001 | $162,000 | 16% |
| 2002 | $187,375 | 16% |
| 2003 | $217,000 | 16% |
| 2004 | $238,600 | 10% |
| 2005 | $254,900 | 7% |
| 2006 | $247,000 | -3% |
| 2007 | $225,000 | -9% |
| 2008 | $184,900 | -18% |
| 2009 | $178,500 | -3% |
| 2010 | $180,000 | 1% |
| 2011 | $170,000 | -6% |
| 2012 | $175,000 | 3% |
| 2013 | $195,000 | 11% |
| 2014 | $208,167 | 7% |
| change | since 2000 | **49%** |
| | | |

# ប័ណ្ណអនុញ្ញាតបើកបរអន្តរជាតិ (International Driving Permit)

**ដោយៈ ស្តាយ បុណ្យ**

**ទីក្រុងឡូវែលៈ** តើអ្វីទៅជាបណ្ណអនុញ្ញាតបើកបរអន្តរជាតិ?

បណ្ណអនុញ្ញាតបើកបរអន្តរជាតិ គឺជាប័ណ្ណអនុញ្ញាតឱ្យបើកបរនៅក្រៅប្រទេស។ ឧទាហរណ៍ បើយើងមានបណ្ណបើកបរនៅប្រទេសខ្មែរយើង អាចសុំបណ្ណអនុញ្ញាតបើកបរអន្តរជាតិមួយ ដើម្បីអាចបើកបរនៅក្រៅប្រទេសបាន ដូចជាបើកបរនៅសហរដ្ឋអាមេរិកជាដើម។

បងប្អូនខ្មែរយើងមួយចំនួនមិនទាន់យល់ច្បាស់អំពីបណ្ណអនុញ្ញាតបើកបរអន្តរជាតិ (International Driving Permit)។ ដោយសារតែបញ្ហានេះហើយ ទើបពួកគាត់ចាញ់បោកក្រុមហ៊ុនចេញប័ណ្ណអនុញ្ញាតបើកបរអន្តរជាតិក្លែងក្លាយ។

ការប្រើប័ណ្ណអនុញ្ញាតបើកបរអន្តរជាតិបណ្ណក្លែងក្លាយមិនត្រឹមតែចំណាយប្រាក់៩0 ដុល្លារ ឥតប្រយោជន៍ប៉ុណ្ណោះទេ ប៉ុន្តែពួកគាត់ប្រឈមនឹងការចាប់ដាក់ពន្ធនាគារថែមទៀតផង។ បណ្ណអនុញ្ញាតបើកបរអន្តរជាតិនេះ ត្រូវសុំនៅក្នុងប្រទេសខ្មែរ មិនមែនមកសុំពេលដែលខ្លួនបានមកដល់ទឹកដីអាមេរិកនោះទេ។ ក្រសួងចុះបញ្ជីយានយន្ត (RMV) នៅសហរដ្ឋអាមេរិក មិនទទួលស្គាល់រាល់បណ្ណអនុញ្ញាតបើកបរជាអន្តរជាតិទាំងឡាយណាដែលមិនមែនចេញដោយប្រទេសសាម៉ីនោះឡើយ។ (សូមអានសៀវភៅណែនាំសម្រាប់អ្នកបើកបរយានយន្តនៅរដ្ឋម៉ាស្សាឈូសេត ឬ MA Drivers Manual នៅទំព័រទី ១៤៧ កថាខណ្ឌ៣ និង ៤)។ មន្ត្រីប៉ូលីសនៃនាយកដ្ឋានប៉ូលីសក្រុងឡូវែលបានបញ្ជាក់ថា ក្រុមហ៊ុនណាដែលចេញបណ្ណអនុញ្ញាតបើកបរអន្តរជាតិឱ្យអ្នកបើកបរខ្មែរ ដែលមានប័ណ្ណបើកបរពីស្រុកខ្មែរ គឺជាក្រុមហ៊ុនបោកប្រាស់។




សៀវភៅណែនាំសម្រាប់អ្នកបើកបរយានយន្តនៅរដ្ឋម៉ាស្សាឈូសេតបញ្ជាក់បន្ថែមថា អ្នកដែលអាចកាន់បណ្ណអនុញ្ញាតបើកបរជាអន្តរជាតិ ត្រូវតែជាប្រជាជនមកពីប្រទេសដែលជាភាគីនៃ អនុសញ្ញាចរាចរណ៍ផ្លូវគោក ឆ្នាំ១៩៤៩ និង អនុសញ្ញាចរាចរណ៍យានយន្តអន្តរ-អាមេរិកឆ្នាំ១៩៤៣។

មធ្យោបាយស្របច្បាប់ និងត្រឹមត្រូវតែមួយគត់ ដើម្បីអាចបើកបរនៅលើទឹកដីអាមេរិកបាន គឺអ្នកបើកបរត្រូវប្រលងយក Leaner's Permit និងប្រលងដៃចង្កូត៕






តមកពីទំព័រទី ០៩ កម្មវិធីផ្សេងៗនៅក្នុងក្រុង...

នាទីក្រុងឡូវែលរដ្ឋម៉ាស្សាឈូសេត។ ក្រុម River Hawks ដែលបានបិទបញ្ចប់រដូវកាលប្រកួតត្រឹមពិន្ទុ ១៨-១០-៦ និងនឹងឡើងមកការពារតំណែងជើងឯកវាយកូនគោលលើទឹកកក Hockey East Tournament Championship របស់ខ្លួនផងដែរ។ ក្រុមនេះបានឈ្នះជាប់ៗគ្នាក្នុងប្រកួតកាលពីឆ្នាំ២០១៣ និង ២០១៤។ កម្មវិធីប្រកួតដើម្បីសម្រេចរកអ្នកឈ្នះចុងក្រោយជិតឈានចូលមកដល់ហើយ។ ក្រុមវាយកូនគោលលើទឹកកក UMass Lowell

ដែលកំពុងស្ថិតក្នុងចំណាត់ថ្នាក់ក្រុមលេខ១ នឹងប្រកួតនៅថ្ងៃសុក្រ ទី១៣ ខែមីនា វេលាម៉ោង ៧:១៥នាទីយប់។ សំបុត្រទស្សនាមានលក់នៅលើអ៊ិនធើណិតតាមរយ: the Tsongas Center Box Office។ បើលោកអ្នកចង់បានការបញ្ចុះតម្លៃសំបុត្រ២០% សូមសរសេរឃ្លាថា the Greater Merrimack Valley CVB នេះ។

### ៣_Mill City Grows នឹងរៀបចំពិធីជួបជុំអ្នកដាំដំណាំក្នុងក្រុងនៃក្រុងឡូវែល :

ជា លើកដំបូងនៅថ្ងៃសៅរ៍ ទី២១ ខែមីនា ពីម៉ោង១១ព្រឹកដល់ម៉ោងពារសៀលនៅសាលា Middlesex Community College, Lowell




Campus ។ ពិធីនេះនឹងប្រមូលផ្តុំអ្នកដាំដំណាំដើម្បីចាប់ផ្តើមរដូវកាលដាំដំណាំថ្មីរួមគ្នា។ កម្មវិធីនេះមានបញ្ចូលសិក្ខាសាលាបង្ហាញរបៀបដាំដំណាំដោះដូរគ្រាប់ពូជទស្សនាខ្សែភាពយន្តភ្លក់អាហារអ្នកស្រុកឡូវែល និងកម្មវិធីច្រើនទៀត។ អ្នកចូលរួមអាចចូលរួមស្តាប់ក្នុងសិក្ខាសាលាអំពីការធ្វើជីកំប៉ុស ការដាំដំណាំលើដំបូលផ្ទះ ការថែពូជដំណាំ ការចម្អិនអាហារល្អដើម្បីសុខភាព ការបង្ការសត្វល្អិត និងការសម្តែងក្បាច់គុណពាក់ព័ន្ធនឹងការថែសួន! ក្រុមប្រធានយុវជនក្នុងមូលដ្ឋាននឹងចែករម្លែកដំបូន្មានល្អៗស្តីពីវិធីក្នុងការចូលរួមក្នុងកិច្ចការសង្គម និងការធ្វើខ្លួនឱ្យក្លាយជាមនុស្សពិសេស ដូចជាការថែសម្មស្សតាមបែបធម្មជាតិ និងការប្រើប្រាស់ផលិតផលថែសម្មស្ស និងធ្វើឧបករណ៍ វាស់ស្ទង់នីវ៉ូទឹក។ ភ្ញៀវពិសេស Mareleen Manos-Jones នឹងធ្វើបទបង្ហាញអំពីសារសំខាន់អំពីសត្វដែលពាំលម្អងផ្កាដូចជាប្រភេទសត្វមេអំបៅ (Monarch butterfly) និងវិធីដែលអាចធ្វើបាន ដើម្បីទាក់ទាញឱ្យសត្វទាំងនេះមករស់នៅក្នុងសួនដំណាំរបស់យើង។

**សូមអានព័ត៌មានបន្ថែមនៅគេហទំព័រ www.millcitygrows.org**



ឌឹ ខេមបូឌា ដេលី The Cambodia Daily

ដំណឹងប្រែសម្រួលពីភាសាអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ខេមបូឌា ដេលី

# នាយករដ្ឋមន្ត្រីៈ គ្មាន គ.ជ.ប. ថ្មីទេ ប្រសិនបើមិន បញ្ឈៀសបាននូវពហិការមិនចូលសភា

**ដោយ ហ៊ុល រស្មី | February 26, 2015- Cambodia Daily**

លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានមានប្រសាសន៍កាលពីថ្ងៃពុធថា លោកនឹងមិនអនុញ្ញាតឱ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប.) ទ្វេបក្សថ្មីបង្កើតឡើងបានទេ លុះត្រាតែបក្សប្រឆាំងយល់ព្រមទៅនឹងច្បាប់ថ្មីដែលនឹងបែងចែកជាថ្មីនូវអាសនៈសភារបស់គណបក្សណាមួយដែលធ្វើពហិការមិនទទួលយកអាសនៈរបស់ខ្លួនបន្ទាប់ពីការបោះឆ្នោត។

លោកក៏បានព្រមានជាថ្មីដល់គណបក្សសង្គ្រោះជាតិកុំបង្កឱ្យមានបដិវត្ត ដោយលោកនិយាយថា ពួកគេនឹងប្រឈមនឹងកំហឹងដ៏ខ្លាំងពីកងទ័ពប្រសិនបើពួកគេធ្វើមែននោះ។

ថ្នាក់ដឹកនាំបក្សប្រឆាំងលោក សម រង្ស៊ី និងលោក កឹម សុខា បានដឹកនាំតំណាងរាស្ត្រ៥៥រូបរបស់គណបក្សសង្គ្រោះជាតិក្នុងការធ្វើពហិការមិនទទួលយកអាសនៈរបស់ខ្លួនរយៈពេល១០ខែ បន្ទាប់ពីការបោះឆ្នោតឆ្នាំ២០១៣ ដែលពួកគេនិយាយថា មានការលួចបន្លំសន្លឹកឆ្នោតច្រើន ហើយបានបញ្ចប់ពហិការទៅវិញ នៅពេលដែលលោក ហ៊ុន សែន បានសន្យាកែទម្រង់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតសម្រាប់ការបោះឆ្នោតលើកក្រោយ។

លោកនាយករដ្ឋមន្ត្រីបានមានប្រសាសន៍កាលពីថ្ងៃពុធថា លោកមិនបណ្តោយឱ្យមានពហិការបែបនេះកើតឡើងជាថ្មីទេ ហើយថា លោកនឹងប្រើសំឡេងភាគច្រើនរបស់គណបក្សប្រជាជនកម្ពុជានៅសភាជាតិ ដើម្បីរារាំងកំណែទម្រង់ដែលបានសន្យាហើយនោះមិនឱ្យអនុម័តបានទេ។

លោក ហ៊ុន សែន មានប្រសាសន៍ថា "ច្បាប់បោះឆ្នោតដែលនឹងដាក់សុំការអនុម័តនៅពេលខាងមុខ គួរតែដាក់ឱ្យហើយទៅសមាជិកសភានៃគណបក្សណាដែលមិនចូលរួមឱ្យសភាឱ្យតាមការកោះអញ្ជើញរបស់ព្រះមហាក្សត្រចាត់ទុកថាជាការបោះបង់ចោលអាសនៈ"។

លោកមានប្រសាសន៍ថា "បើឯងមិនចូលឱ្យសភាគជបនឹងបែងចែកអាសនៈរបស់អ្នកទៅឱ្យបក្សផ្សេងទៅ។ ឱ្យវាឆាប់ចប់។ បើមិនអ៊ីចឹងទេ វានឹងមិនឆាប់ចប់ទេ។ ឱ្យអ្នកចាញ់មិនដែលយល់ព្រមឱ្យទទួលលទ្ធផលឧទេ"។

លោកមានប្រសាសន៍ថា "រឿងទី២គឺថា បើអ្នកឯងមិនយល់ព្រម នឹងប្រើអាចាស់ដដែល។ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតនឹងជាគណៈកម្មាធិការចាស់ ហើយច្បាប់ផ្សេងទៀតនឹងនៅជាច្បាប់ចាស់ ពីព្រោះនឹងមិនមានអ្វីថ្មីជំនួសទេ"។

ក្រុមការងារមកពីខាងគណបក្សប្រជាជនកម្ពុជានិងខាងគណបក្សសង្គ្រោះជាតិ សព្វថ្ងៃកំពុងព្រាងការប្តូរឱ្យមានច្បាប់បោះឆ្នោតថ្មី។ លោក សម រង្ស៊ី មានគម្រោងនឹងជួបរដ្ឋមន្ត្រីក្រសួងមហាផ្ទៃលោក ស ខេង នៅថ្ងៃសៅរ៍ ដើម្បីចរចា១០ចំណុចនៃការមិនព្រមព្រៀងគ្នាដែលនៅ

**តទៅទំព័រទី១៥**

# Prime Minister Says No New NEC Unless Boycotts Barred

**By HulReaksmey | February 26, 2015 - Cambodia Daily**

Prime Minister Hun Sen said Wednesday that he would not allow the new bipartisan National Election Committee (NEC) to form unless the opposition agrees to a new law that will redistribute the parliamentary seats of any party that boycotts its seats after an election.

He also again warned the opposition CNRP not to foment revolution, saying they would face the wrath of the armed forces if they did.

Opposition leaders Sam Rainsy and KemSokha led the CNRP's 55 lawmakers on a 10-month boycott of their seats after the 2013 election, which they said was marred by fraud, and ended it only when Mr. Hun Sen pledged to reform the NEC for the next election.

The prime minister said Wednesday that he could not allow such a boycott to happen again, and that he would use the CPP's numerical majority in the National Assembly to prevent the pledged reforms being legislated.

"The election law that will be put for approval in the future should be ready to state that the lawmakers of any party that doesn't enter [parliament] when the king convenes, that will be considered an act of relinquishing the seats," Mr. Hun Sen said.

"If you don't enter [parliament], the NEC will distribute your seat to other political parties. This will end [problems] quickly. If not, they will not end. [The losers] will never agree [to the results]," he said.

"The second thing is that if you do not agree, the old things will be used. The NEC will be the old one and other laws will be the old ones because there will be no new things for replacement," he said.

Working groups from the CPP and CNRP are presently drafting changes to the election law. Mr. Rainsy is due to meet with Interior Minister SarKheng on Saturday to negotiate 10 points of disunity that remain over the new election law, and said Wednesday that Mr. Hun Sen's threat surprised him.

"This sounds rather strange because this is the first time I have heard such an idea. I have been following the talks from the working groups and they have never released such a provision," Mr. Rainsy said.

The CNRP president said he did not have a stance on the proposal but that it might conflict with the Constitution.

"Once a party has gained a number of votes and seats from the electorate, according to the Constitution, how legal would it be to say that party will lose all their seats?" he said.

"I have to consult my with colleagues and lawyers to see whether this conflicts

**Continued to Page 25**

# កាកបាទក្រហមចែកអំណោយអង្ករផ្ទររឱ្យទៅប្រជាពលរដ្ឋក្នុងឃុំរកា

**ដោយ មុិច ដារ៉ា | MARCH 3, 2015**

មន្ត្រីបាននិយាយថា អង្កររាប់ពាន់គីឡូដែលកាកបាទក្រហមកម្ពុជាបានចែកឱ្យទៅគ្រួសារក្រីក្រក្នុងខេត្តបាត់ដំបង រួមទាំងអ្នកភូមិរស់នៅក្នុងឃុំរកា ដែលផ្ទុះករណីឆ្លងមេរោគអេដស៍ផងនោះ ត្រូវបានប្តូរជំនួសកាលពីម្សិលមិញក្រោយពីអ្នកភូមិតវ៉ាថា អង្ករទាំងនោះផ្អូរ។

កាលពីថ្ងៃទី១៦ ខែកុម្ភៈ លោកស្រី ប៊ុន រ៉ានី ប្រធានកាកបាទក្រហមកម្ពុជាដែលត្រូវជាភរិយារបស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានចុះទៅឃុំរកា ក្នុងស្រុកសង្កែ ដើម្បីចែកអំណោយអង្ករ មី មុង និងប្រាក់ប្រហែល២៥ដុល្លារក្នុងម្នាក់ៗសម្រាប់អ្នកភូមិក្នុងមូលដ្ឋាន និងអ្នកភូមិមកពីស្រុកក្បែរៗគ្នាជិត៥.០០០នាក់។

ប៉ុន្តែនៅពេលអ្នកភូមិត្រឡប់ទៅដល់ផ្ទះវិញ ហើយបើកបាវអង្ករឡើង ពួកគាត់មានការភ្ញាក់ផ្អើលយ៉ាងខ្លាំងដោយសារតែវាមានពណ៌ក្រហម និងធុំក្លិនឃ្មិះៗដែលមិនស័ក្តិសមសម្រាប់មនុស្សបរិភោគ។

លោក ចាន់ សុផល អភិបាលខេត្តបាត់ដំបង បានមានប្រសាសន៍ថា កាលពីម្សិលមិញអាជ្ញាធរខេត្តបានយកអង្ករថ្មីទៅដល់ឃុំនេះហើយ។ លោកបានមានប្រសាសន៍ថា "នៅពេលយើងចែកអង្ករ

**តទៅទំព័រទី ២៣**

# Red Cross Replaces Rotten Rice Donated to HIV-Hit Commune

**BY MECH DARA | MARCH 3, 2015**

Thousands of kilograms of rice donated by the Cambodian Red Cross to impoverished families in Battambang province, including residents of HIV-hit Roka commune, had to be replaced Monday after villagers complained it was rotten, officials said.

On February 13, Cambodian Red Cross President Bun Rany, the wife of Prime Minister Hun Sen, visited Roka commune in Sangke district to distribute rice, noodles, mosquito nets and about $25 each to more than 5,000 local villagers and residents of neighboring districts.

But when villagers got home and opened their sacks of rice, they were hit by the foul stench of spoiled, discolored grains that were not fit for human consumption.

On Monday, provincial authorities returned to the commune with a fresh shipment, said provincial governor Chan Sophal. "When we first distributed the rice, it sparked anger among them because the charity that donated it [the Red Cross] had stored it in a humid warehouse for too long," he said.

In Roka commune on Monday, Sam Lorn-who at 81 years old is one of many elderly victims of the mysterious HIV outbreak that has infected nearly 240 residents-said villagers had also grown impatient **Contimued to Page 25**

ឌឹ ខេមបូឌា ដេលី The Cambodia Daily

ដំណឹងប្រែសម្រួលពីភាសាអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ខេមបូឌា ដេលី

## មន្ត្រីគណបក្សសង្គ្រោះជាតិតវ៉ាប្រឆាំងប្រធានគណបក្សខេត្តសៀមរាប

**ដោយ យី សុវុឌ្ឍី** | **MARCH 3, 2015**

មន្ត្រីគណបក្សសង្គ្រោះជាតិជាង៥០នាក់ស្វះស្វែងឱ្យដកលោកស្រី កែ សុវណ្ណរតន៍ សមាជិកសភាពីប្រធានគណបក្សនេះក្នុងខេត្តសៀមរាបដែលបានធ្វើឡើងតាមរយៈការគំរាមកំហែងថា នឹងនាំយកករណីរបស់ខ្លួនមកកាន់រាជធានីភ្នំពេញ ដោយបានធ្វើការតវ៉ាកាលពីម្សិលមិញរយៈពេលពីរម៉ោងនៅខាងក្រៅទីស្នាក់ការកណ្តាលគណបក្សប្រឆាំងស្ថិតក្នុងខណ្ឌមានជ័យ។

ក្រុមអ្នកតវ៉ារួមមានមន្ត្រីដែលមានតួនាទីប្រតិបត្តិថ្នាក់ស្រុកនិងថ្នាក់ខេត្តរបស់គណបក្សសង្គ្រោះជាតិ ហើយបានចោទប្រកាន់លោកស្រី សុវណ្ណរតន៍ ដែលជាភរិយារបស់លោក យឹម សុវណ្ណ ប្រធានគណៈកម្មាធិការប្រតិបត្តិរបស់គណបក្សថា បក្ខពួកនិយម និងចាយវាយថវិកាខុសប្រក្រតី។

លោក សេង រដ្ឋា អនុប្រធានក្រុមសម្របសម្រួលគណបក្សប្រឆាំងក្នុងស្រុកក្រឡាញ់ខេត្តសៀមរាបបានមានប្រសាសន៍ថាមន្ត្រីគណបក្សបានធ្វើដំណើរមករាជធានីភ្នំពេញស្នាក់នៅមួយយប់ដើម្បីដាក់ករណីរបស់ខ្លួនដោយផ្ទាល់ទៅមេដឹកនាំគណបក្ស។

លោកបានមានប្រសាសន៍ថា "គោលបំណងសំខាន់របស់យើងនៅថ្ងៃនេះ គឺមកជួបលោក សម រង្ស៊ី ប្រធានគណបក្សសង្គ្រោះជាតិ និងលោក កឹម សុខា អនុប្រធានគណបក្ស ដើម្បីសុំឱ្យលោកទាំងពីរផ្លាស់ប្តូរលោកស្រី កែ សុវណ្ណរតន៍ សមាជិកសភាមណ្ឌលសៀមរាបដោយដកលោកស្រីចេញពីប្រធានក្រុមការងារ ហើយដាក់ជំនួសដោយសមាជិកសភាមួយរូបផ្សេងទៀត"។

លោក រដ្ឋា បានមានប្រសាសន៍ថា លោកបារម្ភថា លោកស្រី សុវណ្ណរតន៍ នឹងដឹកនាំគណបក្សសង្គ្រោះជាតិតាមលំអានដូចគ្នានឹងគណបក្សប្រជាជនកម្ពុជា។




លោក រដ្ឋា បានមានប្រសាសន៍ថា "យើងបានឃើញគណបក្សប្រជាជនកម្ពុជាដឹកនាំដោយមានការប្រកាន់បក្ខពួកនិយម និងបំផ្លាញប្រទេសជាតិ ហើយយើងក៏បានឃើញចំណុចតូចៗមួយចំនួនទៀតផងដែរនៅក្នុងគណបក្សសង្គ្រោះជាតិក្នុងខេត្តសៀមរាប ដែលពួកគេចង់ធ្វើដូចនេះដែរ ប៉ុន្តែយើងចង់ឱ្យមានការដឹកនាំតាមបែបប្រជាធិបតេយ្យ"។ **តទៅទំព័រទី ២៣**

## Opposition Officials Demonstrate Against Siem Reap Party Chief

**BY KHY SOVUTHY | MARCH 3, 2015**

More than 50 CNRP officials seeking the removal of lawmaker Ke Sovannaroth as the party's head in Siem Reap province carried through with a threat to bring their case to Phnom Penh, demonstrating Monday for two hours outside the opposition's headquarters in Meanchey district.

The protesters included officials with executive positions on the CNRP's provincial and district levels, and accuse Ms. Sovannaroth-who is married to Yim Sovann, chairman of the party's executive committee-of nepotism and spending irregularities.

Seng Ratha, deputy chief of the opposition's coordinating group in Siem Reap's Kralanh district, said the party officials had traveled to Phnom Penh overnight to put their case directly to party leaders.

"Our important purpose today is to come meet with [CNRP] President Sam Rainsy and Vice President Kem Sokha to ask them to change Ke Sovannaroth, the Siem Reap province lawmaker-to remove her as working group chief and be replaced by any other lawmaker," he said.

Mr. Ratha said he was afraid Ms. Sovannaroth would lead the CNRP down the same path as the ruling CPP.

"We've seen the CPP, led by nepotism, destroying the country, and we have also seen some small points [in the CNRP in Siem Reap] that they want to do this too, but we want to be led as a democracy," Mr. Ratha said.

Blek Sothea, a member of the CNRP's Siem Reap working group, said although Ms. Sovannaroth has led the opposition for more than a decade in the province, she has done little to improve the party's standing there.

"She has led for three mandates but it has not developed. She is nepotistic and she appoints people who are close to her or support her," Mr. Sothea said.

"She removed more than 10 activists who sacrificed all their energy and property [for the party] and appointed her own officers because they are 'yes men' officials."

After the protest in front of his offices had gone on for about two hours, Mr. Rainsy, the opposition leader, emerged to speak to the protesters, congratulating **Continued to Page 17**

**តមកទំព័រទី ១៤**

## នាយករដ្ឋមន្ត្រីៈ គ្មាន គ.ជ.ប. ថ្មីទេ...

សេសសល់ទាក់ទិននឹងច្បាប់បោះឆ្នោតថ្មី និងបាននិយាយកាលពីថ្ងៃពុធថា ការគំរាមរបស់លោក ហ៊ុន សែន បានធ្វើឱ្យលោកភ្ញាក់ផ្អើល។

លោក រង្ស៊ី បាននិយាយថា "ស្តាប់ទៅចម្លែកបន្តិច ពីព្រោះនេះជាលើកដំបូងហើយដែលខ្ញុំបានឮគំនិតបែបនេះ។ ខ្ញុំកំពុងតាមដានការចរចាពីក្រុមការងារ ហើយពួកគេមិនដែលបង្ហាញលក្ខខណ្ឌបែបហ្នឹងទេ"។

ប្រធានគណបក្សសង្គ្រោះជាតិរូបនេះបាននិយាយថា លោកមិនមានជំហរអំពីសំណើនេះទេ ប៉ុន្តែថា វាអាចផ្ទុយនឹងរដ្ឋធម្មនុញ្ញ។

លោកបាននិយាយថា "យោងតាមរដ្ឋធម្មនុញ្ញ ពេលណាគណបក្សមួយបានទទួលសំឡេងឆ្នោតនិងអាសនៈពីមណ្ឌលបោះឆ្នោត តើតាមលក្ខណៈផ្លូវច្បាប់គណបក្សនោះនឹងបាត់បង់អាសនៈទាំងអស់របស់ខ្លួនយ៉ាងម៉េចកើតទៅ?"។

"ខ្ញុំត្រូវពិគ្រោះជាមួយសហសេវិកនិងមេធាវីរបស់ខ្ញុំ ដើម្បីឱ្យដឹងថាតើការនេះផ្ទុយនឹងគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យ និងប៉ះពាល់ឆន្ទៈប្រជាពលរដ្ឋ ឬយ៉ាងណា"។

ក្នុងសុន្ទរកថារបស់លោក ហ៊ុន សែន ដែលថ្លែងនៅពេលបិទបញ្ចប់ការប្រជុំប្រចាំឆ្នាំរបស់ក្រសួងមហាផ្ទៃកាលពីថ្ងៃពុធលោកនាយករដ្ឋមន្ត្រីក៏បានប្រាប់កម្លាំងសន្តិសុខនៅទីនោះឱ្យគោរពកាតព្វកិច្ចរបស់ខ្លួនក្នុងការការពាររដ្ឋាភិបាលរបស់លោក។

លោកបានមានប្រសាសន៍ថា "ទាំងកងទ័ពនគរបាលរាជអាវុធហត្ថ និងរដ្ឋបាលស៊ីវិលទាំងអស់មិនអាចអព្យាក្រិត្យរវាងគណបក្សនយោបាយនិងរដ្ឋបានទេ។ នេះជាអ្វីដែលខ្ញុំចង់បញ្ជាក់ឱ្យច្បាស់"។

លោក ហ៊ុន សែន បានមានប្រសាសន៍ថា "ប្រសិនបើគណបក្សឈ្លោះគ្នា អ្នកទាំងអស់គ្នាអាចទៅបញ្ឈប់ជម្លោះដោយមិនកាន់ជើងខាងណា។ ប៉ុន្តែពេលដែលគណបក្សមួយបំពានរដ្ឋត្រូវមានការឆ្លើយតបភ្លាម"។

លោក ហ៊ុន សែន ក៏បានឡុកឡាយដាក់គណបក្សសង្គ្រោះជាតិដោយនិយាយថា ប្រសិនបើខ្លួនព្យាយាមផ្តួលរំលំរដ្ឋាភិបាលរបស់លោក ខ្លួននឹងទទួលបរាជ័យភ្លាម។

ក្នុងពេលធ្វើពហិការរបស់គណបក្សសង្គ្រោះជាតិកាលពីឆ្នាំមុន លោក រង្ស៊ី បានឡុកឡាយជាសាធារណៈដាក់លោក ហ៊ុន សែន ដោយនិយាយថា គាត់អាចដើរផ្លូវរបស់ប្រធានាធិបតីអ៊ុយក្រែន វិកទ័រ យ៉ាណូកូវិច ដែលត្រូវគេបណ្តេញចេញពីអំណាច។

លោកនាយករដ្ឋមន្ត្រីបានមានប្រសាសន៍កាលពីថ្ងៃពុធថា "ពេលអ្នកឯងឮអំពីអ៊ុយក្រែនអ្នកឯងចង់ធ្វើតាមអ៊ុយក្រែន។ មានអីបើអ្នកឯងធ្វើតាមអ៊ុយក្រែនការប្រយុទ្ធគ្នានឹងកើតឡើង"។

លោកបានមានប្រសាសន៍ថា "ប្រទេសជាច្រើនដែលមានបដិវត្តពណ៌កំពុងតែងាប់...។ ប្រទេសលីប៊ីម៉េចហើយ? ប្រទេសអេហ្ស៊ីបម៉េចហើយ ? ប្រទេសទុយនីស៊ីគ្រាន់បើជាងប្រទេសផ្សេងបន្តិច ហើយអេហ្ស៊ីបគ្រប់គ្រងដោយកងទ័ព"។ "ទីនេះមិនមែនជាអ៊ុយក្រែនទេ។ ទីនេះមិនមែនជាលីប៊ីទេ"។

**និត (រាយការណ៍បន្ថែមដោយ Alex Willemyns)**

ឌឹ ខេមបូឌា ដេលី The Cambodia Daily

ដំណឹងប្រែសម្រួលពីភាសាអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ខេមបូឌា ដេលី

# ច្បាប់បោះឆ្នោតព្រាងរួច ប៉ុន្តែការទាមទាររបស់លោក ហ៊ុន សែន មិនច្បាស់លាស់

ដោយ: ហ៊ុល រស្មី និង អេឡិក វិល្លឹមមីនស៍ | March 3, 2015

លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន កាលពីថ្ងៃច័ន្ទបានអបអរសាទរចំពោះការបញ្ចប់ការចរចាទាក់ទិននឹងការកែប្រែច្បាប់បោះឆ្នោតជាតិ និងបានមានប្រសាសន៍ថា គណបក្សសង្គ្រោះជាតិបានយល់ព្រមបញ្ចូលក្នុងច្បាប់នេះនូវសំណើរបស់លោកក្នុងការដកកៅអីសភាពីគណបក្សនយោបាយណាដែលធ្វើពហិការមិនចូលសភាក្រោយពីការបោះឆ្នោត។

លោក សម រង្ស៊ី មេដឹកនាំបក្សប្រឆាំងបានមានប្រសាសន៍ថា សេចក្តីព្រាងច្បាប់បានបញ្ចប់កាលពីល្ងាចថ្ងៃច័ន្ទ ហើយតាមការដឹងរបស់លោកមិនមានបញ្ចូលសំណើលើកឡើង ដោយលោក ហ៊ុន សែន ទេ ប៉ុន្តែបានបន្ថែមថា ការពិភាក្សាគ្នាថែមទៀតអំពីសំណើនេះនឹងត្រូវធ្វើបន្ត។

ថ្លែងនៅវិទ្យាស្ថានជាតិអប់រំនាព្រឹកនោះ លោក ហ៊ុន សែន បានសរសើររដ្ឋមន្ត្រីក្រសួងមហាផ្ទៃលោក ស ខេង និង លោក សម រង្ស៊ី ក្នុងការបញ្ចប់ការចរចាដ៏យូរក្នុងការប្រជុំរយៈពេលបួនម៉ោងកាលពីល្ងាចថ្ងៃសៅរ៍។

ការសម្របសម្រួលមួយចំនួនសម្រេចបានក្នុងនោះគណបក្សប្រជាជនកម្ពុជាយល់ព្រមឱ្យបន្ថែមអាសនៈសភាថ្មីពីរទៀត ហើយគណបក្សសង្គ្រោះជាតិយល់ព្រមទៅនឹងការកាត់បន្ថយរយៈពេលធ្វើយុទ្ធនាការបោះឆ្នោត ហើយលោក ហ៊ុន សែន បានមានប្រសាសន៍ថា ដំណោះស្រាយនេះគួរឱ្យសរសើរ។

មុនពេលបន្ថែមថា សំណើផ្ទាល់របស់លោកដែលសំដៅបញ្ចៀសភាពជាប់គាំងក្រោយការបោះឆ្នោតក៏ត្រូវបានយល់ព្រមដែរនោះ លោក ហ៊ុន សែន បានមានប្រសាសន៍ថា "ខ្ញុំសូមអបអរសាទរផងនៅថ្ងៃនេះ។ កាលពីថ្ងៃសៅរ៍ គឺថ្ងៃទី២៨ ខែកុម្ភៈឆ្នាំ២០១៥នេះ ឯកភាពគ្នាហើយច្បាប់បោះឆ្នោត"។

លោក ហ៊ុន សែន បានមានប្រសាសន៍ថា "ឱ្យតំណាងរាស្ត្រជាប់ឆ្នោតឱទាំងនោះដែលមិនចូលស្បថដើម្បីយកសុពលភាពរបស់ខ្លួន និងអ្នកដែលមិនចូលប្រជុំឱ្យសភា។ល។...ឱ្យយើងនឹងឃើញអាសនៈរបស់ពួកគេបាត់បង់យ៉ាងម៉េច"។ លោកបានបន្ថែមថា "ពួកគេបានឯកភាពគ្នាហើយ ប៉ុន្តែមិនទាន់បានសរសេរនៅឡើយ។ ពួកគេបានចាប់ផ្តើមសរសេរនៅថ្ងៃនេះ។ សរសេរហើយពួកគេធ្វើសិក្ខាសាលា"។

លោក ហ៊ុន សែន បានមានប្រសាសន៍កាលពីសប្តាហ៍មុនថា លោកនឹងវេតូច្បាប់បោះឆ្នោតថ្មីនេះ ប្រសិនបើសំណើនេះមិនត្រូវបានបញ្ចូលក្នុងច្បាប់នេះទេ។ សេចក្តីប្រកាសដែលចេញក្រោយការចរចាកាលពីល្ងាចថ្ងៃសៅរ៍បាននិយាយថា ចំណុចដែលស្នើឡើងនេះនឹងត្រូវចរចាគ្នាបន្តទៀត។

លោក រង្ស៊ី បានមានប្រសាសន៍នៅថ្ងៃច័ន្ទថា លោកប្រកាន់យកតាមសេចក្តីប្រកាសនោះ ប៉ុន្តែថា សេចក្តីព្រាងច្បាប់នោះត្រូវបានធ្វើបញ្ចប់រួចរាល់ដោយមន្ត្រីមកពីគណបក្សទាំងពីរក្នុងកិច្ចប្រជុំបួនម៉ោងកាលពីល្ងាចថ្ងៃច័ន្ទ។

សំដៅដល់ច្បាប់បោះឆ្នោតជាតិនិងច្បាប់មួយផ្សេងទៀតដែលបង្កើតគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតថ្មីលោក រង្ស៊ី បានមានប្រសាសន៍ថា "ការប្រើពាក្យពេចន៍ចប់ហើយឥឡូវនេះ។ សេចក្តីព្រាងច្បាប់បានបញ្ចប់។ យើងមានសេចក្តីព្រាងច្បាប់ពីរ"។

មេដឹកនាំបក្សប្រឆាំងរូបនេះបាននិយាយថា លោកមិនជឿថា សំណើដែលលើកឡើងដោយលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ជាផ្នែកមួយនៃសេចក្តីព្រាងច្បាប់បញ្ចប់ហើយនេះទេ។

លោក រង្ស៊ី បានមានប្រសាសន៍ថា "យោងតាមសហសេវិករបស់ខ្ញុំដែលបានចូលរួមក្នុងការពិភាក្សាដែលបានបញ្ចប់កន្លះម៉ោងមុននេះ ខ្ញុំមិនដឹងទេ។ ប្រហែលខ្ញុំភ្លេចហើយ ប៉ុន្តែខ្ញុំមិនដឹងអំពីសំណើនេះក្នុងសេចក្តីព្រាងច្បាប់ដែលទើបតែបញ្ចប់នេះទេ"។

"ខ្ញុំប្រហែលទទួលព័ត៌មានខុស ប៉ុន្តែ...ខ្ញុំមិនដឹងអំពីសំណើនេះនៅក្នុងច្បាប់នេះទេ"។

មេដឹកនាំគណបក្សប្រឆាំងរូបនេះមិនអធិប្បាយបន្ថែមអំពីសំណើ ឬការអធិប្បាយរបស់លោក ហ៊ុន សែន កាលពីថ្ងៃច័ន្ទទេ។

ទាំងគណបក្សប្រជាជនកម្ពុជាទាំងគណបក្សសង្គ្រោះជាតិបានឯកភាពគ្នាកាលពីថ្ងៃសៅរ៍ថានឹង

តទៅទំព័រទី២៤

# Election Law Drafted; Status of Hun Sen's Demand Unclear

**By Hul Reaksmey and Alex Willemyns | March 3, 2015**

Prime Minister Hun Sen on Monday welcomed the end of talks over changes to the national election law and said the opposition CNRP has agreed to include in the law his proposal to strip National Assembly seats from any political party that boycotts parliament after an election.

Opposition leader Sam Rainsy said that the draft law was completed Monday evening and does not, to his knowledge, include the rule proposed by Mr. Hun Sen, but added that further discussions about the proposal will be held.

Speaking at the National Institute of Education in the morning, Mr. Hun Sen congratulated Interior Minister Sar Kheng and Mr. Rainsy on ending the long-running negotiations in a four-hour meeting on Saturday evening.

A number of compromises were reached, including the CPP allowing two new parliamentary seats to be added and the CNRP allowing for reduced campaign periods, and Mr. Hun Sen said the settlement was commendable.

"I would like to express congratulations today. On Saturday, the 28th of February 2015, the issues regarding the election law were agreed upon," Mr. Hun Sen said, before adding that his own suggestion—meant to avoid post-election deadlocks—had also been agreed upon.

"Those [elected lawmakers] who do not enter to take an oath to obtain their validity and those who do not take part in meetings [of the Assembly] and so on…[we] will see how their seats are lost," Mr. Hun Sen said.

"They agreed on this but they did not write it up yet. They started writing this today," he added. "When they are finished writing, they will organize seminars."

Mr. Hun Sen said last week he would veto the new election law if the rule were not included in the law. A statement released after the negotiations Saturday evening said the suggested provision would be negotiated further.

Mr. Rainsy said Monday he stands by that statement, but that the draft law had been completed by officials from both parties at another four-hour meeting Monday evening.

"The wording is completed now. The draft law is completed. We have the two draft laws," Mr. Rainsy said, referring to the national election law and another law forming the new National Election Committee (NEC).

The opposition leader said he did not believe the prime minister's suggested provision was part of the completed draft law.

"According to my colleagues who attended the discussion that finished half an hour ago, not to my knowledge. I may have forgotten, but I do not know about this provision in the draft law that has just been completed," Mr. Rainsy said.

"I may have been misinformed but…I do not know about this provision being in the law."

The opposition leader declined to comment further about Mr. Hun Sen's proposal or comments Monday.

Both the CPP and CNRP agreed on Saturday to hold further talks to discuss the provision. Deputy Prime Minister Bin Chhin said after Monday's drafting session that the first such meeting could be scheduled for next week.

"This point…was also raised. The CNRP especially has to prepare to discuss the issue and put it to the workshop. And [this must happen] before this law is approved by the National Assembly," Mr. Chhin said.

Mr. Rainsy said in an interview on Sunday that Mr. Kheng indicated during Saturday's talks that the prime minister's proposal may not in fact have to be placed in the draft election law.

"What I heard from Sar Kheng is that the CPP just made a request. There are no deadlines or conditions that it should be in the election law," he said.

"The topic will be discussed, and we will study how it will be worded and its full substance, and we will have to agree…on where to put it: possibly in the Constitution, in the Law on the Election of Members of the National Assembly, possibly in the National Assembly's internal rules, [or] possibly the Law on Political Parties."

Mr. Rainsy said the new election law could be introduced in a special meeting of the parliament as early as this month—despite the remaining talks around Mr. Hun Sen's proposal.

The draft election law will be presented to the National Assembly in tandem with the law to create the new bipartisan NEC, the keystone of election reforms negotiated by the two parties last year.

**(Additional reporting by Khuon Narim).**

Continued from page 15

## Opposition Officials Demonstrate...

them for coming to Phnom Penh but saying he had to consider the opinions of others in Siem Reap.

"Thank you to people who love the party and have opinions about how to strengthen the party to win at the next election," Mr. Rainsy told the protesters, explaining he would visit Siem Reap soon to survey popular opinion.

"We have to meet each other again in Siem Reap and we will call all the people from everywhere who have different opinions, and we will listen all together."

Ms. Sovannaroth said by telephone after the protest that she had overseen growth in the opposition's vote in Siem Reap-from 29,000 in 2003 to over 140,000 in 2013-and was not afraid of any inquiry into her activities.

"The opposition party is never corrupt because we do not go to cut down trees or do anything wrong," Ms. Sovannaroth said.

"Please show evidence for the accusations that I have spent money without transparency," she added. "I will leave it to the local and national leaders of the CNRP to evaluate me."

sovuthy@cambodiadaily.com



## ទំព័ររឿងកំប្លែងខ្មែរ ដោយ : ស្វាយ បុណ្យ

### ១_តែប៉ុណ្ណឹងទេអ្អែ ?

ស្ត្រីម្នាក់បានទៅលេងមិត្តភក្តិគាត់ដែលបែកគ្នាយូរ ។ បន្ទាប់ពីនៅសម្រាន្តលេងនៅផ្ទះសម្លាញ់បានពីរបីថ្ងៃរួចមកគាត់ក៏បានលាគ្នា ។ មុននឹងចាកចេញស្ត្រីជាភ្ញៀវបានហុចប្រាក់ប្រាំពាន់រៀលទៅឱ្យកូនស្ត្រីម្ចាស់ផ្ទះ ។ ក្មេងនោះយកលុយដាក់ក្នុងហោប៉ៅប្លុកដោយឥតអរគុណអ្វីមួយម៉ាត់ ។ ម្តាយនាងតូចឃើញដូច្នេះគាត់មិនត្រឹមតែអន់ចិត្តនឹងភាពខ្វះសុជីវធម៌របស់កូនប៉ុណ្ណោះទេ គាត់ខ្មាសមិត្តភ័ក្តិយ៉ាងខ្លាំងផងដែរ ។ ភ្លាមនោះគាត់អូសដៃកូនចូលក្នុងបន្ទប់ស្ងាត់ៗរួចប្រដៅថា :

**ម្តាយ :** កូនឯងមិនត្រូវធ្វើបែបនេះទេ! ពេលមានគេឱ្យលុយ ដូច្នេះក្រែងកូនដឹងថា ត្រូវធ្វើយ៉ាងម៉េចហើយអ្អែ ?

**កូន :** (យកដៃអេះក្បាល អេះអុញ) ខ្ញុំអត់ចាំថាធ្វើម៉េចផង!

**ម្តាយ :** ម៉េចថាអត់? កូនគួរយកគំរូតាមម៉ាក់! កូនមានចាំទេ ម៉ាក់និយាយម៉េចពេលប៉ាកូនឱ្យលុយម៉ាក់ម្តងៗ?

ឮសម្តីនេះ នាងតូចនឹកឃើញពាក្យម្តាយ ។ នាងងក់ក្បាល រួចដើរសំដៅទៅរកស្ត្រីដែលឱ្យលុយនាងមុននេះ ។

**កូន :** (និយាយរាងលើកសម្លេង) មានតែប៉ុណ្ណឹងទេអ្អែ?

-----

### ២_ជេរឱ្យអស់ចិត្ត

ពេលតុលាការកំពុងសួរដេញដោលជនជាប់ចោទ ស្រាប់តែគាត់ស្រែកចំទាលជេរតុលាការយ៉ាងចាស់ដៃ ។ ឮដូច្នេះប្រធានអង្គជំនុំជម្រះខឹងខ្លាំងណាស់ គាត់បានប្រាប់ទៅជនជាប់ចោទថា :

**ចៅក្រមៈ** អ្នកឯងធ្វើនេះគឺជាទង្វើប្រមាថតុលាការ ។ ខ្ញុំនឹងចេញបង្គាប់ឱ្យពិន័យអ្នកឯងជាប្រាក់ប្រាំម៉ឺនរៀល ។

ឮពាក្យនេះ ជនជាប់ចោទនៅស្ងៀម ។ ភ្លាមនោះគាត់លូកដៃរាវក្នុងហោប៉ៅទំនងដូចជាកំពុងរកអ្វីម្យ៉ាង ។ ឃើញដូច្នេះ លោកចៅក្រមឃាត់ ត្បិតស្មានតែគាត់លូកយកប្រាក់មកបង់ថ្លៃពិន័យ ។

ចៅក្រមៈ អ្នកឯងមិនបាច់បង់ឥឡូវ ចាំបង់ពេលក្រោយក៏បានដែរ!

**ជនជាប់ចោទ :** ខ្ញុំមិនមែនចង់បង់ឥឡូវទេ! តែខ្ញុំរកមើលលុយក្រែងគ្រប់អាចជេរថែមបានពីរបីម៉ាត់ទៀត ៕




CONWAY
INSURANCE AGENCY

រយៈពេល២៥ឆ្នាំ ភ្នាក់ងារធានារ៉ាប់រងខុនវេយបានបម្រើសហគមន៏ដោយធានារ៉ាប់រងគ្រប់មុខប្រកបដោយគុណភាពនៅតំបន់ញូអ៊ីងឡែន ។

យើងខ្ញុំជាភ្នាក់ងារបំពេញសេវាគ្រប់មុខដូចខាងក្រោម :

ការធានារ៉ាប់រងគ្រួសារ
- រថយន្ត
- ផ្ទះ
- ផ្ទះល្វែង
- គ្រឿងអលង្ការ
- វត្ថុសិល្បៈ
- វត្ថុបុរាណ

ការធានារ៉ាប់រងជំនួញ
- អចលនវត្ថុ
- សុវត្ថិភាពជំនួញ (Liability)
- សុវត្ថិភាពជំនាញ (Professional Liability)
- រីកខ៏ខម (Worker's Compensation)
- បនដស៏ (Bonds)
- អ្នកមើលថែឡាន និងការ៉ាស់ឡាន
- ធានារ៉ាប់រងពិការភាព និងជីវិត
- កម្មវិធីពិសេសផ្សេងៗទៀត

CONWAY
INSURANCE AGENCY

77 E. Merrimack Street. Lowell, MA 01852
Tel: 978-454-5054|Fax 978-453-2480
www.conwayinsurance.com
សូមទាក់ទងមក : ហ្វីលីប មុត, អ្នកគ្រប់គ្រង

Red Rose
ភោជនីយដ្ឋាន RESTAURANT
កូលាបក្រហម ម្ចាស់ថ្មី _ម្ហូបឈ្ងុយឆ្ងាញ់

Pailin Plaza
716 Middlesex St. Ste 1
Lowell, MA 01851

អញ្ជើញមកចូលរួមមិន ខុសបំណងទេ សូមអរគុណ!

Mon-Sun
8am -8pm



បាយសាច់ជ្រូកពងទាចៀន



គុយទាវអូរឬស្សី



មីកន្តាំង



បបរគ្រឿង

*ម្ហូបឆ្ងាញ់ជាងមុន តែតម្លៃនៅថោក ដូចមុនដដែល
*សេវាកម្មរហ័សទាន់ចិត្ត និងរួសរាយរាក់ទាក់

(978) 452-5400



KhmerPost USA

# ខ្មែរផុសស.រ.អា

## មានទទួលធ្វើការងារបន្ថែម

- កាសែត
- Banner
- នាមប័ណ្ណ
- ទស្សនាវដ្តី
- ធៀបការ
- ខួបកំណើត
- Poster
- សំបុត្របុណ្យ
- សំបុត្រឡើងគេហដ្ឋាន




សូមទាក់ទងមកតាមរយៈទូរស័ព្ទ:

**Tel: 978-656-8141**

Email: khmerpostusa@gmail.com

# មេធាវីថីមាសស្ទីលីអាណូស

- ជួយធ្វើតាក់ដោយមិនបាច់មានលេខសូស្យាល់ (Filling Tax without Social Security)
- ជួយធ្វើគ្រីនកាត ១០ ឆ្នាំអោយបានបន្ទាប់ពីមានការលែងលះគ្នា (Divorced 10 year Green Card)
- ជួយធ្វើគ្រីនកាត ២ ឬ ១០ឆ្នាំ (Help with 2 or 10 year Green Card)
- ជួយអ្នកដែលនៅលើសកំណត់អោយបាននៅក្នុងប្រទេសបន្តទៀត (Help Overstay Bars)
- ជួយការពារកុំអោយគេបញ្ជូនទៅស្រុកវិញបន្ទាប់ពីបានប្រព្រឹត្តិខុសច្បាប់ (Criminal Deportation)
- ជួយរៀបចំឯកសារធានាឪពុកម្តាយកូននិងបងប្អូនមកអាមេរិច (Get Parents, Children and Sibling Here)
- ជួយរៀបចំឯកសារសំរាប់ធានាប្តីប្រពន្ធ ឬគូរដណ្តឹងមកអាមេរិច (Get Spouse or Fiancé Here)
- ជួយរៀបចំឯកសារសុំលែងលះប្តីប្រពន្ធ (Divorce, only in Massachusetts)
- ជួយការពារ និងធ្វើជាតំណាងក្នុងរឿងគ្រោះថ្នាក់ចរាចរណ៍ (Car Accident, only in Massachusetts)
- ជួយធ្វើការតវ៉ានៅចំពោះមុខក្រុមប្រឹក្សាសាលាឧទ្ធរណ៍ផ្នែកអន្តោប្រវេសន៍ (BIA Immigration Appeals)
- ជួយធ្វើឯកសារចូលសញ្ជាតិដល់សាម៉ីខ្លួន និងកូនៗរបស់លោកអ្នក (N-400 and N-600)
- ជួយធ្វើគ្រីនកាតថ្មីបន្ទាប់ពីត្រូវគេលួច ឬបាត់បង់ (I-90, Replacement Green Card)
- ជួយសុំកាតធ្វើការ (Work Card)
- ជួយធ្វើលិខិតធ្វើដំណើរចេញចូល (Re-entry Permit)

# Thomas Stylianos Law Offie

## 287 Appleton Street, Suit 205 Lowell, MA 01852

# Tel: 978-459-5000

## E-mail: Tom@stylianoslaw.com

Attorneys' only licensed in Massachusetts

តមកពីទំព័រទី ២០

# ឯកសារផ្ទៃក្នុងនៃអគ្គមេបញ្ជាការ...

តំបន់ចំណុចកំពស់ ៥០០ (70.92) :

. មានការទាស់ដណ្ដើមគ្នាកាន់កាប់តំបន់នេះព្រោះមុនពេលសមាហរណកម្មចុងក្រោយ តំបន់នេះកាន់កាប់ដោយភាគីខ្មែរក្រហម ។

៣. ព្រំដែនកម្ពុជា-ឡាវ : សរុបមានបាតុភាព ១លើក

. នៅស្រែវែងស្ថិតនៅក្នុងស្រុកសៀមប៉ាង ខេត្តស្ទឹងត្រែងចំណុចXA (28.52) ទល់មុខស្រុកម៉ឿងខុង ខេត្តចំប៉ាសាក់ (ឡាវ) មានប្រជាជនឡាវមករស់នៅទីនោះតាំងពីសម័យសង្គមរាស្ត្រនិយម ក្នុងឆ្នាំ១៩៦៤ ប៉ុន្តែរបបប៉ុលពតឆ្នាំ១៩៧៥-១៩៧៩ ពួកនេះបានចូលទៅរស់នៅក្នុងទឹកដីឡាវវិញ លុះដល់ឆ្នាំ១៩៧៩ រហូតមកដល់បច្ចុប្បន្ន ពួកគេបានត្រឡប់មករស់នៅចំណុចនេះវិញ ។

## II. ការដោះស្រាយបញ្ហាព្រំដែនជាមួយបណ្ដាប្រទេសជិតខាង :

១. ជាមួយភាគីថៃ :

. យោងតាមអនុក្រឹត្យលេខ ៦៧ ចុះថ្ងៃទី១៩/០៩/១៩៩៥ របស់រាជរដ្ឋាភិបាល ស្ដីអំពីបង្កើតគណកម្មការព្រំដែនទូទៅ និងគណកម្មការរក្សាសន្តិភាពព្រំដែនទូទៅ ។ អគ្គបញ្ជាការបានចាត់តាំងគណកម្មការព្រំដែនថ្នាក់យោធភូមិភាគ,អង្គភាពជំនាញ និងនាយទាហានប្រចាំការនៅតាមបណ្ដាច្រកដែលបានកំណត់រួមមាន : ការិយាល័យទំនាក់ទំនងព្រំដែនកម្ពុជា-ថៃ នៅច្រកប៉ោយប៉ែត និងក្រុមទំនាក់ទំនងការងារ តាមច្រកព្រំដែន ២៣ក្រុម ។

. ឈរលើស្មារតីសន្តិភាព-មិត្តភាពជាមួយប្រទេសជិតខាង គណកម្មការរក្សាសន្តិភាពព្រំដែនទូទៅ និងក្រុមការងារព្រំដែនគ្រប់ថ្នាក់ដែលបានចាត់តាំងហើយ បានខិតខំព្យាយាមដោះស្រាយវិវាទខាងលើ ដោយចាត់តាំងប្រតិភូគ្រប់ថ្នាក់ជួបចរចារជាមួយសមភាគីថៃនៅតាមទីកន្លែង និងពេលវេលាកើតហេតុ ជៀសវាងបានទាំងស្រុងការប៉ះទង្គិចដោយអាវុធ ដូចជា :

* ករណីបឹងត្រកួន

ឯកឧត្តមអគ្គមេបញ្ជាការ កងយោធពលខេមរភូមិន្ទ បានធ្វើការចរចារផ្ទាល់ជាមួយអគ្គបញ្ជាការថៃ កាលពីថ្ងៃទី០៧-០៣-១៩៩៩ បានបញ្ឈប់ការសាងសង់សំណង់ប៉ុស្តិ៍ព្រំដែនថៃនៅច្រកបឹងត្រកួន រហូតមកដល់សព្វថ្ងៃ ។

* ករណីឡាក់ ២៧ :

អគ្គមេបញ្ជាការបានចាត់តាំងតំណាងទីចាត់ការព្រំដែន និងតំណាងយោធភូមិភាគ៥ កងពលលេខ៧ បានទៅជួបចរចារជាមួយភាគីថៃ ដោះស្រាយដោយសន្តិភាព ។

២. ការដោះស្រាយជាមួយភាគីវៀតណាម-ឡាវ :

. កន្លងមកអគ្គបញ្ជាការ កងយោធពលខេមរភូមិន្ទ បានដឹកនាំគណៈប្រតិភូជាន់ខ្ពស់ធ្វើទស្សនៈកិច្ចជាផ្លូវការ នៅសាធារណៈរដ្ឋសង្គមនិយមវៀតណាម និងសាធារណៈរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ពីថ្ងៃទី២០-២៦ ខែ០៧ ឆ្នាំ១៩៩៩ក្នុងគោលបំណងពង្រឹងសហប្រតិបត្តិការយោធា និងលើកកំពស់ចំណងមិត្តភាពជាមួយបណ្ដាប្រទេសជិតខាង ។

. ក្នុងអំឡុងពេលទស្សនៈកិច្ចនេះ សមភាគីទាំងពីរបានឯកភាពជាគោលការណ៍រួម ក្នុងការដោះស្រាយរាល់ការវិវាទព្រំដែនដោយសន្តិវិធី គោរពតាមបណ្ដាកិច្ចព្រមព្រៀង អនុសញ្ញា-សន្ធិសញ្ញា ដែលគណកម្មការព្រំដែនជាតិបានឯកភាពគ្នា ។

. ថ្នាក់ដឹកនាំយោធាទាំង៣ប្រទេសបានឯកភាពគ្នាទៀតថា និងខិតខំផ្លាស់ប្ដូរប្រតិភូថ្នាក់យោធាភូមិភាគរវាងគ្នានិងគ្នា ៦ខែម្ដង ថ្នាក់ខេត្ត ៣ខែម្ដង ដើម្បីពង្រឹងសហប្រតិបត្តិការមិត្តភាពសន្តិភាពតាមបណ្ដោយព្រំដែន ជៀសវាងដាច់ខាតការប្រឈមមុខដោយអាវុធ ។

## III. ការវាយតំលៃ សន្និដ្ឋាន និងបទពិសោធន៍ :

១. ការវាយតំលៃ :

. បាតុភាពព្រំដែនដែលកើតមានឡើងកន្លងមកបណ្ដាលមកអំពី :

ក/ ឯកសារដែលអាណានិគមបារាំងបន្សល់ទុកមកពុំទាន់មានភាពសុក្រឹត្យនៅមានចំណុចល្អ និងចំណុចអាក្រក់ខ្លះដែលត្រូវធ្វើការកែសំរួលជាមួយបណ្ដាប្រទេសជិតខាង ។ ឧទាហរណ៍ ខ្សែប្រេវិយេពុំមែនជាខ្សែព្រំដែន គ្រាន់ជាខ្សែគ្រប់គ្រងរដ្ឋបាលប៉ុណ្ណោះ ។

. ជាមួយភាគីថៃ បារាំងបានបន្សល់ទុកនៅឯកសារ និងផែនទីព្រំដែនអមសន្ធិសញ្ញា 1904-1907 ។ ឯកសារនេះមានភាពច្បាស់លាស់ខាងផ្លូវច្បាប់ជាងខ្សែប្រេវិយេ ។

ខ/ ដោយសារសង្គ្រាមផ្ទៃក្នុងរ៉ាំរ៉ៃអូសបន្លាយរយៈពេលយូរ បញ្ហាព្រំដែនពុំទាន់បានប្រមូលផ្ដុំដោះស្រាយជាមួយបណ្ដាប្រទេសជិតខាង ។ ភូមិករដែលតាមជាយដែន ត្រូវជម្លៀសចេញ ហេដ្ឋារចនាសម្ព័ន្ធត្រូវបំផ្លាញ ពិសេសក្នុងរបបប្រល័យពូជសាសន៍ប៉ុលពតប្រជាជនត្រូវបាត់បង់នូវកម្មសិទ្ធិ ។

គ/ បណ្ដាលមកពីលក្ខណៈបច្ចេកទេសនៃផែនទីមិនទាន់មានភាពសុក្រិត្យនិងបច្ចេក វិទ្យាខ្ពស់នៅឡើយ បង្កឱ្យមានការលំបាកដល់ការកំណត់ទីតាំងព្រំសីម៉ា ។

ឃ/ បណ្ដាលមកពីការរីករាលដាលនៃប្រជាជននៃបណ្ដាប្រទេសជិតខាង

២. ការសន្និដ្ឋាន

ពិនិត្យជារួមរយៈពេល៦ខែ ដើមឆ្នាំ១៩៩៩ នៅតាមបណ្ដោយព្រំដែនជាមួយបណ្ដាប្រទេសជិតខាងមានភាពទំនាស់ជាច្រើនលើក ច្រើនសារ លើច្រើនតំបន់ ។ ហេតុការណ៍នេះអាចអោយយើងសន្និដ្ឋានបានថា : ក្រោយពេលដែលយើងបានរួបរួមគ្នា បណ្ដាប្រទេសជិតខាងក៏រៀបចំនយោបាយ ព្រំដែនរបស់គេឡើងវិញដែរ ។

៣. បទពិសោធន៍

ក្នុងរយៈពេលដំណើរការដោះស្រាយ រាល់បាតុភាពដែលកើតមានឡើងតាមបណ្ដោយព្រំដែន អគ្គមេបញ្ជាការ កងយោធពលខេមរភូមិន្ទ ដកស្រង់បទពិសោធន៍មួយចំនួន :

ក/ ការរៀបចំគណកម្មការរក្សាសន្តិភាពព្រំដែនទូទៅកម្ពុជា-ថៃ បង្កលក្ខណៈងាយស្រួលក្នុងការទប់ស្កាត់ទាន់ពេលវេលា បណ្ដាបាតុភាពវិវាទ រវាងប្រទេសទាំងពីរ ។

ខ/ តួនាទីរបស់យោធាទាំង២ប្រទេស នៅតាមព្រំដែនមានសារៈសំខាន់ដល់ការដោះស្រាយរាល់ វិវាទតាមព្រំដែន ។

គ/ ទីកន្លែងណាដែលមានភូមិករប្រជាជនរស់នៅតាមបណ្ដោយព្រំដែនកុះករ គឺទីកន្លែងនោះពុំសូវមានទំនាស់ព្រំដែនទេ ។

ឃ/ នៅទីកន្លែងណាដែលមានកងកំលាំងប្រដាប់អាវុធរបស់យើងឈរជើង មានការងាយស្រួលក្រួតពិនិត្យ ដោះស្រាយ ។

សំណូមពរ

១-រាជរដ្ឋាភិបាលមានផែនការកសាងហេដ្ឋារចនាសម្ព័ន្ធនៅបណ្ដាមូលដ្ឋានជាប់ព្រំដែន ដើម្បីគួបផ្សំការងារការពារប្រទេស និងអភិវឌ្ឍន៍ប្រទេសជាតិ ។

២-ចំពោះបញ្ហាដោះមីនតាមបណ្ដោយព្រំដែន ត្រូវមានការឯកភាពជាមួយគណកម្មការព្រំដែន និងក្រសួងការពារជាតិ ដើម្បីធានាឱ្យបានទាំងផ្នែកបច្ចេកទេសទាំងផ្នែកសន្តិសុខជាតិ ។

៣-យកចិត្តទុកដាក់អភិវឌ្ឍន៍តំបន់ព្រំដែនច្រើនជាងកន្លែងផ្សេងៗ

៤-រាជរដ្ឋាភិបាលពង្រឹងសមត្ថភាព និងផ្ដល់លទ្ធភាពគ្រប់គ្រាន់ឱ្យគណៈកម្មការព្រំដែនជាតិ បំពេញកិច្ចការបានល្អ ។

៥-រាជរដ្ឋាភិបាលចំណាយថវិកាដើម្បីកសាងទីកន្លែងចាំបាច់មួយចំនួន នៅតាមព្រំដែន (គំរោងកសាងលំអិត និងធ្វើជូននៅពេលក្រោយ) ។

៦-រាជរដ្ឋាភិបាលមានគោលនយោបាយច្បាស់លាស់ចំពោះកងកំលាំងប្រដាប់អាវុធ និងប្រជាជន ដើម្បីលើកទឹកចិត្តដល់អ្នកដែលស្ម័គ្រចិត្តទៅរស់នៅតាមបណ្ដោយព្រំដែន ។

៧-រាល់គំរោងការសាងសង់យុទ្ធសាស្ត្រសំខាន់ៗនៅព្រំដែន ស្នើអោយមានការរួមយោបល់ពិភាក្សារបស់អគ្គមេបញ្ជាការ ក្រសួងការពារជាតិ គណៈកម្មការព្រំដែនជាតិ ។

៨-ពង្រាយកំលាំងយោធាព្រំដែន និងនគរបាល ទៅព្រំដែនជំនួសអោយកំលាំងទ័ពស្រួច ។

៩-តាមព្រំដែន កន្លែងណាដែលភាគីទាំងសងខាងបានឯកភាពគ្នារួច ត្រូវបោះបង្គោលអោយហើយឆាប់ មិនត្រូវរង់ចាំរហូតដល់មានការឯកភាពទាំងស្រុង ទើបបោះបង្គោលនោះទេ

១០-ការពង្រឹងកងទ័ពអោយបានរឹងមាំ ត្រូវធ្វើជាចាំបាច់ មិនអាចមើលស្រាលសភាពការណ៍បានឡើយ ។

អាស្រ័យដូចបានរាយការណ៍ជូនខាងលើ សូមសម្ដេចនាយករដ្ឋមន្ត្រី មេត្តាជ្រាបជារបាយការណ៍ ។

សូមសម្ដេចនាយករដ្ឋមន្ត្រី មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ ។

អគ្គមេបញ្ជាការ

នាយឧត្តមសេនីយ៍.ង៉ែត-គីមយ៉ាន

ចម្លងផ្ញើជូន
- ក្រសួងការពារជាតិ
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- គណៈកម្មាធិការព្រំដែនជាតិ
- ឯកសារ-កាលប្បវត្តន៍

ដើម្បីជូនជ្រាប




គំនូសព្រំប្រទល់ដែលវៀតណាមរំលោភ តួរក្រៅផ្លូវការអោយរស្មីកម្ពុជា



# បាញ់ទឹកអប់ដូចម្តេច ទើបក្លិនក្រអូបបានយូរ

**ទឹកអប់ជាគ្រឿងបន្ថែមក្លិនក្រអូបដល់រាងកាយដែលជាទីចាប់ចិត្តចង់ហិតក្លិនម្ចាស់កាយចង់កៀកកើយនៅក្បែរជានិច្ច ។ ប៉ុន្តែថា តើគួរត្រូវធ្វើយ៉ាងណាដើម្បីរក្សាក្លិនក្រអូបបានយូរ?**

ទឹកអប់នឹងសាយក្លិននៅក្នុងអាកាសធាតុ បានល្អនៅពេលស្ថិតនៅលើស្បែកក្តៅឧណ្ហៗដែលមានសរសៃឈាមហូរចុះឡើង ដូចជា កញ្ចឹង.ក កដៃផ្នែកខាងក្នុងសន្លាក់ទាំងឡាយ រួមទាំងជង្គង់ក្រលៀន ចង្កូរទ្រូង និងកជើង ពីព្រោះបរិវេណទាំងនេះមានស្បែកក្តៅឧណ្ហៗជាងបរិវេណផ្សេងៗ ហើយប្រសិនបើចង់ឱ្យក្រអូបដូចក្លិនខ្លួននោះ សាកល្បងបាញ់ទឹកអប់លើក្រាស់សិតសក់បាញ់ក្នុងចម្ងាយល្មមឱ្យក្លិនតំណក់ទឹកអប់ចាប់ជាប់នឹងក្រាស់ទើបសិតសក់ជាក្រោយ ។ ប៉ុន្តែជាតិអាល់កុល និងសារធាតុផ្សេងៗក្នុងទឹកអប់អាចធ្វើឱ្យសក់ខូចបាន ហេតុដូចនេះត្រូវឧស្សាហ៍ថែសក់ជាប្រចាំផង ។

សម្រាប់ស្ត្រីវ័យសិក្សា ឬយុវវ័យទាំងឡាយ សូមណែនាំឱ្យសាកល្បងប្តូរមកបន្ថែមក្លិនក្រអូបក្នុងកាបូប ឬកន្សែងដៃជំនួសវិញ ដោយយករបស់ដែលមានក្លិនក្រអូបមកដាក់រួមក្នុងប្រអប់មួយ ហើយបាញ់ទឹកអប់ដាក់ដុំសំឡីទៅក្នុងប្រអប់នោះក្លិនទឹកអប់របស់អ្នកនឹងរក្សាបានយូរបំផុត ។ វិធីនេះប្រើបានផងដែរជាមួយខោអាវសំលៀកបំពាក់ក្នុងទូល្អជាងការប្រោះព្រំទឹកអប់លើខោអាវ ព្រោះអាចធ្វើឱ្យមានស្នាមលើសំលៀកបំពាក់បាន ។

ចំណែកវិធីថែរក្សាទឹកអប់មិនឱ្យមានក្លិនប្លែកខុសប្រក្រតី គួរទុកដាក់ទឹកអប់ក្នុងកន្លែងដែលត្រជាក់តែមិនមានសំណើម និងមិនត្រូវកម្តៅថ្ងៃខ្លាំង បើចង់ទុកដាក់ឱ្យបានល្អនោះ អាចដាក់ក្នុងប្រអប់សុញ្ញាកាសក៏បាន ៕


ហ្វេយ៍មឹកខេប ផ្ទះសម្រាប់ពិធីបុណ្យសព

**Fay McCabe Funeral Home**

105 Moore Street. Lowell, MA 01852

**978-459-9222**

**បម្រើសហគមន៍ខ្មែរដោយការយកចិត្តទុកដាក់ កិត្តិយស និងការគោរពជាង៣០ឆ្នាំមកហើយ**

- Serving All Faiths — បម្រើសេវាកម្មគ្រប់ជំនឿ
- Traditional Funerals — កម្មវិធីបុណ្យសពជាលក្ខណៈប្រពៃណី
- Cremation Services — មានផ្តល់សេវាបូជាសព
- Pre Arranged Funerals — រៀបចំរោងមុនកម្មវិធីបុណ្យសព

***លោកអ្នកនឹងក្រុមគ្រួសារទទួលបាននូវការយកចិត្តទុកដាក់ និងការបម្រើល្អប្រពៃពីទីនេះ ។***

www.faymccabe.com



Locates 1 mile from Glory Buddhist Temple, between Gorham St. & Lawrence St.

ទីកន្លែងនៅចំងាយ១ម៉ាយពីវត្តពន្លឺពុទ្ធចក្ក ចន្លោះផ្លូវ Gorham St. & Lawrence St.

***មានបុគ្គលិកនិយាយភាសាខ្មែរ***

## តមកពីទំព័រទី ១៥ មន្ត្រីគណបក្សសង្គ្រោះជាតិតវ៉ាប្រឆាំង...

លោក ប្លេក សុធា សមាជិកក្រុមការងារគណបក្សសង្គ្រោះជាតិខេត្តសៀមរាបបានមានប្រសាសន៍ថា បើទោះជាលោកស្រី សុវណ្ណរតនី បានដឹកនាំគណបក្សប្រឆាំងរយៈពេលជាង១ទសវត្សរ៍ក្នុងខេត្តនេះក៏ដោយ ក៏លោកស្រីបានធ្វើការងារតិចតួចតែប៉ុណ្ណោះដើម្បីកែលម្អគណៈវចនាសម្ព័ន្ធគណបក្សនៅទីនោះ។

លោក សុធា បានមានប្រសាសន៍ថា លោកស្រីបានដឹកនាំបីអាណត្តិមកហើយ ប៉ុន្តែមិនបានអភិវឌ្ឍអ្វីទេ។ លោកស្រីបក្ខពួកនិយម ហើយលោកស្រីតែងតាំងអ្នកដែលជិតស្និទ្ធ ឬគាំទ្រលោកស្រី។ លោកស្រីចោទសមាជិកដទៃទៀតថា បានគាំទ្រគណបក្សនេះ ឬគណបក្ស នោះ"។

លោកបានបន្ថែមថា "លោកស្រីបានដកសកម្មជនជាង១០នាក់ ដែលបានបូជាកម្លាំងកាយចិត្ត និងលះបង់ទ្រព្យសម្បត្តិរបស់ខ្លួនដើម្បីគណបក្ស ហើយបានតែងតាំងមន្ត្រីរបស់ខ្លួន ពីព្រោះពួកគេជាមន្ត្រីដែលចាំតែ ហៃអើ ប៉ុណ្ណោះ"។

បន្ទាប់ពីការតវ៉ានៅមុខការិយាល័យរបស់លោករយៈពេលប្រហែលពីរម៉ោងមក លោក សម រង្ស៊ី មេដឹកនាំគណបក្សប្រឆាំងបានចេញមកនិយាយជាមួយអ្នកតវ៉ា ដោយអបអរសាទរដល់ពួកគាត់ដែលបានមកដល់រាជធានីភ្នំពេញ ប៉ុន្តែបានលើកឡើងថា លោកត្រូវពិចារណាពីយោបល់របស់អ្នកផ្សេងទៀតនៅក្នុងខេត្តសៀមរាបសិន។

លោក សម រង្ស៊ី បាននិយាយទៅកាន់អ្នកតវ៉ាថា "អរគុណបងប្អូនទាំងអស់ដែលស្រឡាញ់គណបក្ស ហើយមានយោបល់ថាតើត្រូវពង្រឹងគណបក្សរបៀបណាឱ្យទទួលបានជ័យជម្នះនៅការបោះឆ្នោតលើកក្រោយ" ដោយលោកបានពន្យល់ថា លោកនឹងធ្វើដំណើរទៅខេត្តសៀមរាបនៅពេលឆាប់ៗនេះ ដើម្បីស្ទាបស្ទង់មតិយោបល់របស់ប្រជាពលរដ្ឋ។

លោកបានមានប្រសាសន៍ថា "យើងត្រូវជួបប្រជុំគ្នាម្តងទៀតក្នុងខេត្តសៀមរាប ហើយយើងនឹងកោះហៅមនុស្សមកពីគ្រប់ទីកន្លែងទាំងអស់ដែលមានមតិយោបល់ខុសៗគ្នា ហើយយើងនឹងស្តាប់យោបល់ទាំងនោះទាំងអស់គ្នា"។

លោកស្រី សុវណ្ណរតនី បានមានប្រសាសន៍តាមទូរស័ព្ទបន្ទាប់ពីការតវ៉ាថា លោកស្រីបានឃើញការកើនឡើងសំឡេងឆ្នោតរបស់គណបក្សប្រឆាំងក្នុងខេត្តសៀមរាបពី២៩.០០០សំឡេងក្នុងឆ្នាំ២០០៣ ដល់ជាង១៤០.០០០សំឡេងក្នុងឆ្នាំ២០១៣ ហើយលោកស្រីមិនបារម្ភពីការស៊ើបអង្កេតលើសកម្មភាពរបស់លោកស្រីឡើយ។

លោកស្រី សុវណ្ណរតនី បានមានប្រសាសន៍ ថា "គណបក្សប្រឆាំងមិនដែលប្រព្រឹត្តអំពើពុករលួយទេ ពីព្រោះយើងមិនបានកាប់ឈើ ឬធ្វើអ្វីខុសឡើយ"។ លោកស្រីបានបន្ថែមថា "សូមបង្ហាញភ័ស្តុតាងពីការចោទប្រកាន់ដែលថា ខ្ញុំបានចាយវាយលុយដោយគ្មានតម្លាភាពមក។ ខ្ញុំនឹងទុកឱ្យថ្នាក់ដឹកនាំមូលដ្ឋាន និងថ្នាក់ជាតិរបស់គណបក្សសង្គ្រោះជាតិវាយតម្លៃរូបខ្ញុំចុះ"៕

**សារុន**

## តមកពីទំព័រទី ១៤ កាកបាទក្រហមចែកអំណោយអង្ករផ្អួរ...

លើកទី១ បានធ្វើឱ្យពួកគាត់ខឹងសម្បាដោយសារតែអំណោយអង្ករដែលឱ្យកាកបាទក្រហមបានចែកនោះស្តុកទុកក្នុងឃ្លាំងដែលមានសំណើមយូរពេក។

នៅក្នុងឃុំរការកាលពីម្សិលមិញ លោកតា សំ ឡូន វ័យ៨១ឆ្នាំ ដែលស្ថិតក្នុងចំណោមជនរងគ្រោះវ័យចំណាស់ជាច្រើននាក់ក្នុងករណីផ្ទុះការឆ្លងមេរោគអេដស៍ដ៏អាថិកំបាំងដែលបានឆ្លងទៅអ្នកភូមិជិត២៤០នាក់នោះ បាននិយាយថា អ្នកភូមិកាន់តែខឹងថែមទៀតដោយសារតែរង់ចាំរយៈពេលបីសប្តាហ៍ទម្រាំអង្ករថ្មីមកដល់។

លោកតាបាននិយាយអំពីការចែកអំណោយលើកដំបូងថា "ពេលយើងបើកឱ្យបាវអង្ករឡើងអង្ករធុំក្លិនអាក្រក់ ឡើងពណ៌ក្រម និងពុកផុយ"។ លោកតាបាននិយាយទៀតថា គាត់បានទទួលទានអង្ករនោះអស់ខ្លះហើយ។

លោក ខៀវ កាញារីទ្ធ រដ្ឋមន្ត្រីក្រសួងព័ត៌មានបានបញ្ចេញទស្សនៈតាមទំព័រហ្វេសប៊ុករបស់លោកកាលពីម្សិលមិញ បន្ទាប់ពីទទួលបានដំណឹងអំពីកំហុសឆ្គងមិនគួរកើតនេះ។

